N° 6
R-6 5-2-53

ព្រះរាជាណាចក្រកម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

INDOCHINE
DÉPÔT LÉGAL

# ទស្សនាវដ្ដី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៦

ខែកុម្ភៈ ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥២-១៩៥៣

# ព្រះរាជាណាចក្រ កម្ពុជា

BIBLIOTHÈQUE NATIONALE DU CAMBODGE
P.K.2
1952-1953
(6)

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ
ទស្សនាវដ្ដី សំរាប់គ្រូបង្រៀន

បញ្ជីរឿង                                                    ទំព័រ

សេចក្ដីណែនាំ ........................................ ៣
ឧត្ដមដ្ឋាន និង មធ្យមដ្ឋានទី ២ ភាសា ........................ ១១
មធ្យមដ្ឋានទី ១ ភាសា ........................ ១៩
អាទិកដ្ឋាន ភាសា ........................ ២៣
បរិច្ឆណដ្ឋាន ភាសា ........................ ៣៤
កុមារដ្ឋាន ភាសា ........................ ៣៨
តែងសេចក្ដីសម្រាប់ប្រថមភូមិបំពេញវិជ្ជា ........................ ៤២
តែងសេចក្ដីសម្រាប់ប្រថមភូមិជាន់ដំបូង ........................ ៤៩
អាទិកដ្ឋាន — នព្វន្ត — រង្វាស់រង្វាល់ ........................ ៥៣
បរិច្ឆណដ្ឋាន — នព្វន្ត — រង្វាស់រង្វាល់ ........................ ៦៤
កុមារដ្ឋាន — នព្វន្ត — រង្វាស់រង្វាល់ ........................ ៦៨
កុមារដ្ឋាន — វត្ថុស្វាធ្យាយន៍ — វិធីបង្ការរោគ ........................ ៧២
បរិច្ឆណដ្ឋាន — វត្ថុស្វាធ្យាយន៍ — វិធីបង្ការរោគ ........................ ៧៨
អាទិកដ្ឋាន — វត្ថុស្វាធ្យាយន៍ — វិធីបង្ការរោគ ........................ ៨៣
លោកនីតិ (គ្រប់ថ្នាក់) ........................ ៩០
មេសូត្រ វត់មាត់ ........................ ៩៣

# សេចក្ដីណែនាំ

## អំពីបង្រៀនអាន

ការបង្រៀនអានជាគោលចារិកធំ ជាវិជ្ជាដើមប្រធាន បើគ្មានវិជ្ជានេះ នឹងរៀនវិជ្ជាអ្វីឯទៀតក៏ពុំបានទេ ក្មេងនឹងចេះដឹងបានដោយសារចេះអានដាច់ហើយ គឺថាចេះមើលអក្សរដាច់ហើយទើបរៀនចំណេះផ្សេង ៗ ទៀតនៅក្នុងសៀវភៅបាន ។

## ១. អំពីបង្រៀនអាននៅកុមារដ្ឋាន

យើងសូមលោកជាគ្រូបង្រៀន ៗ អានពីទំព័រ ១ ទៅទំព័រ ១ ពីមេរៀន ១ ទៅមេរៀន ១ ឲ្យហូរហែតាមសៀវភៅដែលក្រសួងសិក្សាធិការបានបោះពុម្ពរួចហើយនោះ សូមធ្វើតាមរបៀបខាងក្រោមនេះ ។

ដំបូងសូមលោកគ្រូសរសេរតួអក្សរ អក្សរបំបែកហើយនឹងពាក្យដែលត្រូវបង្រៀនទាំងប៉ុន្មាន ទុកនៅក្ដារខៀនបញ្ជរឲ្យស្រេចមុនពេលរៀន លុះដល់ពេលចូលរៀនហើយ សូមឲ្យកូនសិស្សមកឈរដំគង់ជុំវិញលោកគ្រូនៅមុខក្ដារខៀនបញ្ជរ រួចលោកគ្រូចង្អុលអក្សរនោះហើយឲ្យសិស្សទាំងអស់ថាអក្សរនោះតាម ៗ

រួចត្រឡប់ច្រាសទៅវិញ គឺលោកគ្រូថាអក្សរណា ១ ឲ្យកូនសិស្សម្នាក់បង្អុលតួអក្សរនោះ ៗ

សូមធ្វើយ៉ាងនេះបន្តិចម្ដងៗ ដរាបទៅដល់បំបែកអក្សរពួកខ្យល់ <អ> ហើយនឹង <អ៊> រហូតដល់ផ្ទើរផើងនឹងដាក់ពាក្យផ្សេង ៗ

លុះបង្រៀនដល់ត្រង់នេះហើយ លោកគ្រូសួរកូនសិស្សអំពីពាក្យនោះ ៗ កាលណាលោកគ្រូបានពន្យល់ បានឲ្យកូនសិស្សពិនិត្យ បានសួររួចស្រេចហើយ ត្រូវឲ្យកូនសិស្សមើលពាក្យឬសេចក្ដីម្នាក់ម្ដងៗ រួចឲ្យមើលដំណាលគ្នាទាំងអស់ សូមលោកគ្រូចាំថា ឲ្យកូនសិស្សអានច្រើនដងជាប្រយោជន៍ឲ្យវាចេះអានដាច់ ហេតុដូច្នេះសូមកុំប្រញាប់ពេក ត្រូវសាត្រឡប់មកក្រោយរឿយ ៗ ផង គឺត្រឡប់ឲ្យអានមេរៀនមុន ៗ ឡើងវិញពីព្រោះហេតុដូច្នេះបានជាថា មុននឹងបង្រៀនមេរៀនថ្មីតទៅទៀត ត្រូវសាបង្រៀនមេរៀនចាស់មួយរំពេចឡើងវិញ.

## ២.– អំពីបង្រៀនអាននឹងហាត់អក្សរផ្ចង់ជាមួយគ្នា នៅថ្នាក់កុមារដ្ឋាន.

យើងបានដំរាបខាងលើរួចហើយថា បង្រៀនអានត្រូវឲ្យកូនសិស្សប្រយ័ត្នសង្កេតមើលតួអក្សរផង ហើយឲ្យចាំតួអក្សរនោះឲ្យចំណាំនឹងភ្នែក ហើយចំណាំនឹងត្រចៀក លោកគ្រូត្រូវឲ្យកូនសិស្សសរសេរអក្សរនោះ

នៅក្តាខៀន ធ្វើដូច្នេះនឹងមានការហាត់អក្សរផ្ចង់បំពេញទៅលើការបង្រៀនអានផង - គឺឲ្យកូនសិស្សចម្លងអក្សរ ពាក្យ ឬសេចក្តីដែលបានរៀនអានហើយនោះ គឺការហាត់ធ្វើនឹងដៃ ថែមទៅលើការហាត់ដោយភ្នែកនឹងដោយមាត់ លុះដល់បួនដប់អាទិត្យទៅ លោកគ្រូនឹងប្រដៅអក្សរកូនសិស្សម្តង ៗ បាន គឺជំបូងលោកគ្រូថា អក្សរ ឬ ពាក្យ ដែលបានបង្រៀនហើយនោះ ឲ្យវាសរសេរបួចថាជាឃ្លាភ័យ ៗ ឲ្យវាដាក់ ធ្វើដូច្នេះនឹងបានបញ្ជាក់បំណេះកូនសិស្សផង ។

## ៣.– អំពីបង្រៀនអាននៅបរិបូណ្ណដ្ឋាន នឹងអាទិកដ្ឋាន

នឹងឲ្យកូនសិស្សនៅថ្នាក់កុមារដ្ឋានឡើងទៅថ្នាក់បរិបូណដ្ឋានបាន លុះតែវាចេះអានអក្សរដាច់មែនទែនហើយ គឺអានមិនទាក់ មិនរអាក់រអួល ។

ឯរបៀបបង្រៀនអាននៅថ្នាក់ទាំងពីរនេះ ត្រូវធ្វើដូច្នេះវិញ

១ – ដំបូងត្រូវឲ្យអានសេចក្តីជាមួយគ្នាទាំងអស់ ដើម្បីឲ្យកូនសិស្សអានត្រូវសំឡេងគ្នា លោកគ្រូត្រូវអានខាងដើមសេចក្តីជាមួយនឹងវា ជាឲ្យច្បាស់ ៗ អាននេះមិនត្រូវធ្វើបទ ឬ សម្លេងអ្វីទេ ត្រូវថាឲ្យច្បាស់ ៗ ហើយកាប់ ៗ បន្តិចផង កូនសិស្សត្រូវថាឲ្យច្បាស់ ៗ ហាមាត់ល្មមគួរសម ហើយថាគ្រប់ខ្យល់អក្សរ ៗ ការបង្រៀនអានព្រមគ្នានេះជាសេចក្តីបង្ហាត់

សំខាន់ណាស់ បើធ្វើបានតាមត្រឹមត្រូវ - ពីព្រោះជាការនាំឲ្យកូនសិស្សប្រុងប្រយ័ត្នហើយនាំឲ្យមានចិត្តចង់អានគ្រប់គ្នា ។

ការសំខាន់— កុំឲ្យកូនសិស្សច្រៀងៗ នេះជាទម្លាប់អាក្រក់ណាស់ ត្រូវបំបាត់កុំឲ្យមានសោះ ។

២ – លុះបង្រៀនអានព្រមគ្នារួចហើយ លោកគ្រូត្រូវពន្យល់សេចក្ដីដែលបានអាននោះដោយរួសរះ គ្រាន់តែឲ្យកូនសិស្សបានយល់សេចក្ដីដែលវាអាននេះ រួចលោកគ្រូត្រូវពន្យល់ពាក្យពិបាកហើយត្រូវចោទសួរកូនសិស្សឲ្យបានជ្រាបថា វាយល់សេចក្ដីដែលវាបានអានពិតប្រាកដមែនឬទេ ។

៣ – រួចលោកគ្រូត្រូវអានសេចក្ដីនេះតែម្នាក់ឯង កូនសិស្សត្រូវប្រុងប្រយ័ត្នស្ដាប់ លោកគ្រូត្រូវអានឲ្យល្អដើម្បីឲ្យកូនសិស្សយកជាគំរូ ពីព្រោះក្មេងត្រាប់បានដោយងាយណាស់ ។

៤ - រួចលោកគ្រូឲ្យកូនសិស្សអានម្នាក់ម្ដងៗតទៅ ឯអាននេះត្រូវលោកគ្រូចង្អុលសិស្សហៅឲ្យអានតៗគ្នា ប៉ុន្តែកុំហៅតាមជួរកូនសិស្សអង្គុយ ពីព្រោះត្រូវឲ្យវាប្រយ័ត្ន ឃ្លាណាដែលកូនសិស្សអានពុំត្រូវ ឬពុំច្បាស់ត្រូវឲ្យថាឡើងវិញ បើកូនសិស្សនៅតែថាពុំច្បាស់ទៀត លោកគ្រូត្រូវថាឲ្យវាស្ដាប់ហើយឲ្យវាថាតាមឡើងវិញផង លោកគ្រូឲ្យកូនសិស្ស

ឯទៀតអានថា ឃ្លាណាដែលកូនសិស្សម្នាក់អានពុំត្រូវ ឬពុំច្បាស់នោះក៏បាន ពីព្រោះជាការដាស់តឿនប្រាជ្ញាស្មារតីក្មេង ។

៥ - បើនៅសល់ពេលបន្តិចមុននឹងបង្ហើយបង្រៀនអាន លោកគ្រូត្រូវប្រាប់ឲ្យអានព្រមគ្នាទាំងអស់ឡើងវិញបាន ប៉ុន្តែម្ដងនេះត្រូវឲ្យវាអានមានបទ មានសំឡេងត្រូវគ្នា ឃ្លាណាដែលវាអានខុសត្រូវឲ្យថាឡើងវិញ

**សេចក្ដីយល់ឃើញផ្សេងៗ** សូមលោកគ្រូកុំភ្លេចថាការបង្រៀនអានគឺប្រយោជន៍ឲ្យកូនសិស្សចេះអាន កូនសិស្សទាំងអស់គ្នា ១ នាក់ ៗ ត្រូវបានអានដោយរៀងខ្លួនឬបានអានជាមួយនឹងគេ កូនសិស្សត្រូវយល់សេចក្ដីដែលវាបានអាននោះផង ដល់ជិតផុតពេលបង្រៀនអានត្រូវសួរកូនសិស្សឲ្យនិយាយពីសេចក្ដីដែលវាបានអានរួចហើយនោះ ឡើងវិញមាត់ទទេគ្មានសៀវភៅ ។ ទៅថ្នាក់អាចិតស្ថាន ការយល់នេះទុកដូចជា

**ការបង្រៀនអាន ពន្យល់ឲ្យដឹងសេចក្ដី**:- អាចឲ្យលោកគ្រូជ្រាបបានពិតប្រាកដថា កូនសិស្សបានយល់សេចក្ដីអាននោះហើយ ល្អជាជាងចោទសួរទៀតផង ការបង្រៀនអានពន្យល់ឲ្យដឹងសេចក្ដីប្រហែលនឹងការហាត់និយាយណាស់ លោកគ្រូត្រូវប្រាប់អំពីសេចក្ដីកាន់ប្រឡូកនឹងការពន្យល់ឲ្យដឹងសេចក្ដីនោះ ។

បើថ្នាក់អាចិតស្ថានទៅដោយខ្លួនផ្សេងពីគេ របៀបបង្រៀនអាន

ត្រូវតែប្រែដូចមានខាងក្រោមនេះ ប៉ុន្តែគប្បីឲ្យកូនសិស្សចេះអានដាច់ពិតប្រាកដផង ។

១– កាលណាលោកគ្រូពន្យល់យោបល់សេចក្តីអាននោះរួចហើយ លោកគ្រូត្រូវអានសេចក្តីនោះឲ្យកូនសិស្សស្តាប់ ។

២– លោកគ្រូពន្យល់ពាក្យពិបាក ៗ ពន្យល់ក្នុងសេចក្តីអាននោះ

៣ – ឲ្យកូនសិស្សអានម្នាក់ម្តង ។

៤– ឲ្យនិយាយសង្ខេបអំពីសេចក្តីដែលបានអានរួចហើយ ។

## ៤.– អំពីបង្រៀនអាននឹងការហាត់បញ្ចាក់ .

នៅថ្នាក់កុមារដ្ឋាន យើងបានឃើញថាត្រូវប្រើអក្សរក្នុងជាពាក្យ ឬ សេចក្តីបន្តិចបន្តួចឲ្យវាសរសេរថែមទៅលើការបង្រៀនអានផង ឯនៅថ្នាក់បរិវច្ឆណដ្ឋានទីងអាទិកដ្ឋានវិញ ការបង្រៀនអានបានជាប្រយោជន៍ដល់ការហាត់ បង្រៀនពាក្យនឹងថែបនិយាយ ជាការសំខាន់ឲ្យបានចេះតែងសេចក្តីដែរ ។

មេរៀនឲ្យចាំស្ទាត់ដែលក្មេងត្រូវសូត្រមាត់ទទេ ត្រូវមើលជាមុនដូចមានអធិប្បាយខាងលើនេះ ប៉ុន្តែលោកគ្រូត្រូវពន្យល់ពាក្យ ពន្យល់សេចក្តីឲ្យច្រើន ដើម្បីឲ្យកូនសិស្សយល់ជាក់ប្រាកដណាស់ ។

## ៥ .– អំពីអក្សរផ្ចង់ .

យើងបានអធិប្បាយខាងលើហើយថាការបង្រៀនអាននឹងការហាត់អក្សរផ្ចង់ត្រូវធ្វើដំណាលគ្នា ។

ដំបូងកូនសិស្សត្រូវសរសេរតួអក្សរតាមគ្រូ សរសេរនៅក្ដារខៀនបញ្ឈរជួរចុះ បើគ្រូផ្ចិតផ្ចង់សរសេរអក្សរឲ្យល្អ កូនសិស្សដែលធ្វើតាមគ្រូក៏សរសេរអក្សរល្អដែរ ។ ដំបូងគ្រូឲ្យវាសរសេរលើក្ដារខ្លួន រួចត្រូវសរសេរនៅសៀវភៅជាប្រញាប់ក្លាមទៅពីព្រោះក្ដារខ្លួននាំឲ្យធ្ងន់ (រឹង) ដៃក្មេង កូនសិស្សត្រូវសរសេរលើសៀវភៅនឹងខ្មៅដៃ លុះតែវាប្រសប់សរសេរមិនខុសហើយ ទើបឲ្យវាសរសេរនឹងស្លាបប៉ាកកាទឹកខ្មៅបាន មិនត្រូវសរសេរតួអក្សរធំ ៗ ពេកទេ ត្រូវធ្វើតាមតួអក្សរដែលមានក្នុងសៀវភៅសិក្សា ។

បង្រៀនសរសេរអក្សរគ្មានអ្វីជាពិបាកទេ លោកគ្រូទាំងអស់ សុទ្ធតែប្រសប់សរសេរហើយ ប៉ុន្តែយើងសូមរំលឹកមកថា សូមឲ្យកូនសិស្សធ្វើតួអក្សរឲ្យច្បាស់ ៗ ឲ្យត្រឹមត្រូវតាមបែបបទអក្សរនិមួយ ៗ ត្រូវទម្លាប់ក្មេងឲ្យអង្គុយកាន់ដងប៉ាកកា ហើយនឹងដាក់សៀវភៅឲ្យត្រឹមត្រូវ លោកគ្រូត្រូវដើរមើលពីក្រោយខ្នងកូនសិស្សគ្រប់គ្នាកែអក្សរអាក្រក់ សរសេរអក្សរជាគំរូនៅកន្លែងចំហខាងដើមសៀវភៅ ៗ ល ៗ ធ្វើយ៉ាងនេះជាការមានប្រយោជន៍ណាស់ ប៉ុន្តែលោកគ្រូត្រូវចំផ្ចិតផ្ចង់ធ្វើគំរូអក្សរឲ្យបាន

ពេញជាល្អមែនទែន    សូមរំលឹកមកថាត្រូវសំអាតសៀវភៅណាស់ផង បើសរសេរល្អហើយប៉ុន្តែមានប្រឡាក់ទឹកខ្មៅក្រខ្វិកក្រខ្វក់ក៏ពុំមែនល្អដែរៗ

ល. ម៉ានិពូជ៍

ស្រង់ពីទស្សនាវដ្ដីបារាំងសេស - ខេមរៈ

ខែកុម្ភៈ ឆ្នាំ ១៩៣៨

ឆ. ឈ.

---

## ឧត្តមដ្ឋាន

# បុណ្យបុះផែ

ឧកាសបុណ្យដល់ហើយ ក្នុងទន្លេនៅមុខវាំងសឹងមានរបៀបរៀបចំ អុំកដឹកលើទឹកលើគោគភាពថ្ងៃកប់ខ្សែកពីជម្ពូតា តាំងទូកនាក់ តាំងទីស្ថាន ៗ នាំមករស់ញែ្ញងបង្កុំស្រួច នៅអែបនៃបន្ទាំព្រះទីនាំងសុខគេស្រម ទូកនែគហោ កញ្ចាល់ទូវទងជ័យពណ៌ស្រស់ ទៀវស់បក់រវិចបតផិតយាមរក្សាព្រះដំណាក់ផែ ៗ មានកេរ៍ក្រសាលសង់ពាសពន្ធូរពណ៌នានា មានក្បាច់រចនាក្បៀវល្អស្លឹកឈើនឹងក្បឹងអត្ថិសទ ៗ ពេលប្រណាំងដល់ហើយ ទូកង ទូកមួង ចេញត្រសង់ទៀបមុខព្រះពន្លា បដូចនាគាត្រាច់ក្នុងផលស័យ ៗ ស័ព្ទសូរប្រេក៏គ្រឹប ១ អ្នកអុំគោះទឹកជាបង្វាក់មានអ្នកពំចាក់ក្បាច់កណ្តាបសេះឈរទន្ទេងជាទីសំណើចនៃអ្នកមើល ៗ ទូកអុំប្តូទូកងលំអនឹងខ្នកម្រមក្សណ៍ខ្មៅស្រវិល ក្បាលកន្សែងយទន្ទាំ បន្សំនឹងហ្មាបាក់រលេចរចនារស្នាមាសក្ញុំព្រិច ១ លួនលឿនរលេចគួរទស្សនាគយគន់មិនចង់ដាក់ភ្នែក ៗ ទូកមួងច្រើនរបស់ចាម ពុំសូវមានក្បាច់ក្បូរទេ គេសរសើរបង្អាក់ស្មើដៃក្រៅវិស័យ ព្រោះពួកចាមសឹងជំនាញជាញជ័យរាងរៃវទូក ៗ មនុស្សមើលខ្ពលច្រួលដូចទឹកហូរពុំអាចគិតគួរចំនួនឡើយ តាមក្សរមាត់ប្រាំងសឹងនៃ:អានណាន់តាន់តាប់ដមានពស្រ្តា

ព័ណ៌ណាយលេចចំរុះពណ៌នានា គណនាដូចកំពលធំមួយពាសមាត់ទន្លេ ។ ឯអាកាសបក្សាយន្ត្រហើរហ្វៀលផ្ទាត់បន្ទឺស័ព្ទកង្ហារស្នើរស្រុតប្រឹថពី ។ ពន្លឺភ្លឺដូចថ្ងៃដោយប្រទីបផ្កាលាដំរេចនាជារូបសត្វ រូបប្រសាទភ្លឺព្រោងព្រាតឆ្លុះប្រុះទាំងផលស័យ ទឹងសព្ទដូរ្យដន្ត្រីពោះល្វើយល្វេងរស្មីព្រះចន្ទ្រចាំងថែងព្រមទាំងខ្យល់ឧត្តរបក់ផ្សព្វកាយ ជាឱកាសសប្បាយមួយនៃស្រុកយើង ។

លោកគ្រូ ពូវ . អុំ

ស្រង់ចេញពីសេចក្តីសំរាំងលោក ប.ឈុំ

ពន្យល់ពាក្យ– អុឹកធឹកឬអុឹកអធឹក = ( ម.ថ. អុឹកកៈធឹកឬអឹកអៈធឹក) ហុឹកហ៊ាក់ ។

មករ ឬ មង្ករ = ន. ( ឈ្មោះត្រីសមុទ្រមួយយ៉ាងមានខ្លួនធំក្បាលខ្លីក្រមុប ធ្មេញទឹងចង្កូមស្ញាញគួរស្ញើម ឆ្លាមមករ )

ផលស័យឬផលាស័យ = (ម. ផលាសយ. ផល+អាសយ = ទន្លេ)

បង្ហាក់ = ន. ផ្ទាក់បទ ។

ប្ហាប៉ាក់ = ន. សំពត់ដែលគេប៉ាក់ពាសមុខទូក ។

ពស្ត្រាភរណ៍ - ពស្ត្រាភរណ៍ – ន. សំពត់ទឹងគ្រឿងប្រដាប់កាយ

យន្ត្រ ឬ យន្ត = ន. គ្រឿងប្រដាប់ដែលកំរើកបានដោយកម្លាំង

បក្រប្រកបគ្នា

ប្រឹថពី ឬ ប្រថពី ន. ផែនដី

កង្ហារ - ប្រដាប់មានស្លាបវិលដោយកំឡាំងខ្យល់

*វេវចន: អុឹកធឹក ហុឹកហាក់ – រុងរឿង . ខ្លារឹក*

*សទិសព្ទ: ទៀប. ន. ទៀបបាំង ៗ ក. វិ. ទៀបក្លួ ៗ គុះដីតាប ៗ*

## ភ្លេងច្រៀងនិងរាំមនុស្សជាន់ដើម

*ការដែលមានវាចា ចិត្តរញ្ជួយ យ៉ាងខ្លាំងក្នុងខណៈ ដែលមានបុណ្យ ឬ ពិធីផ្សេង ៗ នោះ គេច្រើនចាត់ឲ្យមានលេងល្ខោនហើយមានមនុស្សមកប្រជុំមើលល្ខោនជាច្រើនដែរ ៗ នៅវេលាដែលល្ខោនកំពុងលេងពួកអ្នកមើលល្ខោន ក៏សំដែងអាការកិរិយាទៅតាមឬកពារបស់ពួកល្ខោន គឺធ្វើជាបន្ទាក់ ៗ តាមភ្លេងនិងច្រៀងដូចជាពួកល្ខោន ទើបយើងមើលឃើញអាការរញ្ជួយទាំងល្ខោនទាំងអ្នកមើល ៗ បើពោលតាមច្បាប់ចិត្តវិជ្ជានោះនឹងឃើញថាការរញ្ជួយគ្រប់យ៉ាង ដំបូងគ្រាន់តែរញ្ជួយខ្លួនបន្តិច ៗ*

ទឹងប្រើសូរសំឡេងប្រកបផង ដោយមិនបាច់ប្រឹងសរសេរទឹងសូរសំឡេង ប៉ុន្មានទេ ដល់បន្តិចទៅទើបមានអាការប្រឹងបន្តិច ៗ ឡើង ការព្ឍោយក៏កាន់តែខ្លាំងឡើងជាទ្វេគាគ សឹងឃើញការព្ឍោយគ្រប់សព្វសរសៃ តាំងពួកល្មោន តាំងពួកអ្នកមើលលាន់ឮសូរសព្ទគង់រំពង ៗ មនុស្សសម័យជាន់ដើមមិនមែនគ្រាន់តែមើលល្មោនហើយនៅស្ងៀម ៗ ឬជួយបន្ទរបន្តិច ៗ ប៉ុណ្ណោះទេ គឺគេចូលលេងជាមួយនឹងល្មោនធ្វើតាមល្មោនផង ៗ ពួកនេះយល់ថាមានការណ៍កំបាំងអ្វីមួយនៅក្នុងស្គរ ដែលមើលមិនឃើញថាពុំត្រូវ ហើយសូរស្គរនោះមានអំណាចលាន់ឮដល់ពួកសត្វដែលមើលមិនឃើញនឹងភ្នែក ដូចជាវាមានអំណាចលាន់ឮមកដល់មនុស្សដូច្នោះដែរ ៗ

ស្រង់ចេញពីសេចក្ដីសំរាំងលោក ប. ឈុំ

## ពន្យល់ពាក្យ.–

វាចា= ន. សំដី

អាការ= ន. កិនកេង - កិរិយា - ឫកពា

ការណ៍= ន. ហេតុ - ដំណើរ - ផល

សទិសសព្ទ: = សូរ - ន. សូរកាំភ្លើង ៗ សូរ្យ - ន. សូរ្យគ្រាស់ ៗ សូ - ន. ខ្សែសូ ( ខ្សែពាស ) ៗ

អត្ថពិរុទ្ធ: = អាការ ( រ ) . ឫកពា ( ឫ ) . សូ ( រ ) . គាត ( ត )

សរសៃ ( សរ ) - បន្ទូរ ( រ ) - ការណ៍ ( ណ៍ ) ។

សួរដេញ = នៅវេលាណា ណាដែលមនុស្សជាន់ដើមគេចាត់ឲ្យលេង ល្ខោន ។ មនុស្សដែលមកមើលល្ខោនមានអាការកិរិយាដូចម្ដេចខ្លះ ។ ឥឡូវនេះគេលេងល្ខោនបែបយ៉ាងណាវិញ ។ ល ។

---

## មជ្ឈិមដ្ឋានទី ២

---

### ព្រះសង្ហារប្រទេសកម្ពុជា

ព្រះសង្ហារមានការរចនាដ៏វិចិត្រ ដោយស្នាព្រះហស្ដរបស់ ព្រះមហាក្សត្រិយ៍ពីបុរាណ លោកបានតាក់តែងសំរម្យហើយទ្រង់បាន សម្ភោធិយ៉ាងឧឡារិក កាលសម័យប្រាសាទអង្គរមានរូបភាពដូចតទៅ នេះ នៅត្រង់ផ្នែកកណ្ដាលមានពានមាសពីរជាន់ ដំកល់ព្រះខាន់រាជ្យហើយ រចនាស្លឹកឈ្មៅពន្លឺពន្លកជារង្វង់ស្ទើរគ្រប់ទ្រពីខាងក្រោមជើងពានមកុដរាជ្យ ដាក់ពីលើព្រះខាន់ នៅត្រង់កំពូលមកុដមានឆត្រណារង្សី ហើយមានលំពែង ១ គូខ្វែងគ្នា យកផ្ទៃប្រឈមមុខទៅខាងលើ មានរចនាដោយសំពត់កម្ពៃព្រ មានខ្សែរយមាសតាមជាយរលេចពណ៌ភ្លឺផ្លេក នៅផិតមានលំពែងមាន ចងព្រះភូសារ៉ាំយោលទាំងសងខាង ហើយនៅអមសងខាងមានឆត្រត្រួត ប្រាំជាន់ នៅខាងស្ដាំមានរូបរាជសីហ៍ ខាងឆ្វេងរូបគុជសី ជើងក្រោយ

ជាន់លើបាដា ជើងមុខតោងដងឆត្រត្រួត នៅក្នុងបាដាមានរចនាជាអក្សររ៉ូម៉ាំង ថា៖ “ព្រះចៅក្រុងកម្ពុជា” នៅចំកណ្ដាលលើផ្ទៃព្រះខាន់មានរចនាជាក្បាច់ចណ្ណាលោម ។

ត្រាព្រះសង្ហារនៃប្រទេសខ្មែរយើង នានាប្រទេសស្គាល់ជាយូរអង្វែងមកហើយ ។

(ស្រង់ពីសេចក្ដីសំរាំងលោក ប. ឈុំ)

## ពន្យល់ពាក្យ.-

ព្រះសង្ហារ = ត្រាសម្រាប់ក្សត្រិយ៍

លម្អវិចិត្រ = លម្អប្លែក

សម្ពោធ ឬ សម្ពោធន៍ – ថ្លែងសេចក្ដីរៀបរាប់ក្នុងទីប្រជុំធ្វើ ឬ ឡើង មន្ទីរថ្មីជាដើម

ខ្លារិក = រុងរឿង, ហ៊ឹកហាក់

ឆព្វណ្ណរង្សី = រស្មី ៦ ពណ៌ គឺ ខៀវ - លឿង - ក្រហម - ស - ហង្សបាទ - ផ្លេក ។

(ពន្លឺពេជ្រ) តាមទម្លាប់ច្រើនហៅថា ឆ័ព្វណ្ណរង្សី ប៉ុន្តែគង់សរសេរជាឆព្វណ្ណរង្សីដូច្នោះដែរ ។

ព្រះកូសា = គ្រឿងស្លៀកពាក់សម្រាប់ក្សត្រិយ៍ទ្រង់រាជ្យ ។

បាដា= ដើមទ្រ · ទ្រនាប់

ឧណ្ណលោម= រោមប្រជុំចិញ្ចើម

អក្ខរាវិរុទ្ធ= វិចិត្រ (ត្រ). រម្យ. (ម្យ). សម្ភោធ (ធ). ប្រាសាទ (ទ) ព័ទ្ធ (ទ្ធ). ឆត្រ (ត្រ). រាជសីហ៍ (ហ៍)

សួរចោទ – ព្រះសង្ហារប្រទេសកម្ពុជាមានតាំងពីសម័យណាមក? ។ មានរូបភាពដូចម្តេច? ។ នៅក្នុងបាដាមានចារិកដូចម្តេច? ។ ប្រទេសនានាគេស្គាល់ព្រះសង្ហារនេះឬទេ? ។ ពីព្រោះអ្វី? ។

## បុណ្យចូលឆ្នាំលារ

នៅថ្ងៃចូលឆ្នាំនាម៉ឺនសព្វមុខមន្ត្រី ចូលគាល់ហ្លួងជាម្ចាស់ជីវិត ក្នុងរាំង ។ នៅថ្ងៃជាគំរប់បី គឺថ្ងៃឡើងស័កពេលរសៀល ហ្លួងយាងទៅធ្វើពុទ្ធបូជាក្នុងព្រះវិហារវត្តវិស៊ុន ដ៏មានក្បួនហែជាខ្សែក ។ នោះនៅមុខបង្អស់ គេឃើញដំរីប្រាំសឹងប្រដាប់ដោយគ្រឿងល្អប្រសើរ បន្ទាប់មកពួកទាហានសឹងកាន់ទង់ជ័យប្រទេសជាតិនៅដៃ លំដាប់មកទៀតទាហានកាន់លំពែងស្នែងក្របី ពួកមហោស្រព ពួកពលស្នែងក្រហាម សឹងកាន់ស្គរនៅដៃ តមកទៀតពួកនាម៉ឺនអញ្ជើញគ្រឿងដើរអមឡោម

ហ្វូងដែលគង់លើព្រះសាល្វៀនមាស បិទបាំងដោយក្លសសម្ពួយគូ ក្រោយបំផុតមកទៀត ពួករបាំនឹងពួកបម្រើ ។

កន្ទុកាសនោះ គប្បីគេបង់យល់ចង់ឃើញ ព្រោះកាលចេញទៅ ក្បួនហែដើរទៅដូចប្រក្រតីរហូតដល់វត្ត ប៉ុន្តែត្រឡប់មកវិញ ពួកកញ្ញា នានា ដៃកាន់និទៅនៅគន្ធមាលាចាំស្កាត់ក្បួនហែ ហើយថ្វាយសព្វសាធុការដោយបាចសាចសុគន្ធពិដោរដូចជាប្រឡែងលេងសប្បាយ ទៅលើព្រះរាជា លើពួកទាហាន លើពួកក្បួនហែ នូវអស់ពួកអ្នកឈរមើល យ៉ាងហ្នឹងហើយ គឺជាសណ្ដាប់បុណ្យចូលឆ្នាំ. ។

ស្រង់ចេញពីសេចក្ដីសំរាំងលោក ច. ឈុំ

ពន្យល់ពាក្យ.—

គាល់ហ្វូង : អង្គុយចាំស្ដាប់ព្រះឧត្ការហ្វូង — គាល់ព្រះអង្គម្ចាស់ ទៅលេងទៅសួរម្ចាស់...

ពុទ្ធបូជា : ( ម. ថ. ពុត . ធ: ) បូជាចំពោះព្រះពុទ្ធ

ឧឡារិក : ( ម. ថ. អ៊ុឡារ៉ិក ) ៖ អ៊ិកធិក - ហ៊ឹកហ៊ាក់

មហោស្រព : ( ម . ថ . មហោស្រព ) ន. របាំ

សាល្វៀង: ក្រែសែន ហៅសិវិការ វិញក៏បាន

កញ្ញា : ន. ស្រីក្រមុំ - ស្រីជំទង់

ដៃកាន់និទៅ : ជំមាននៅដៃ

គន្ធៈ (ម. ថ. គន់ធៈ) – ក្លិនគ្រឿងក្រអូប

មាលា: ផ្កាកម្រង

គន្ធពិដោរៈ (ម. ថ. គន្ធៈ) ក្លិនក្រអូបល្អ

ស្គរបោង = នៅថ្ងៃចូលឆ្នាំណានាម៉ឺនសព្វមុខមន្ត្រីធ្វើពិធីអ្វីខ្លះ ៗ នៅថ្ងៃឡើងស័ក ព្រះករុណាទ្រង់យាងទៅទីណា ៗ មានក្បួនហែដូចម្ដេចខ្លះ ។ល។

---

មជ្ឈដ្ឋានទី ១

## រៀនមើល - ហាត់ភាសា

### ប្រយោជន៍នៃវិជ្ជា

វិជ្ជាយកនរជនដែលនៅថោកទាប ឲ្យបានចូលទៅជិតព្រះនរបតីដែលគេទៅជិតបានដោយក្រ ឬមានបុណ្យដ៏ក្រៃលែងជាងព្រះនរបតីទៅទៀត ។

វិជ្ជានាំឲ្យមានវិន័យ វិន័យនាំឲ្យបានសេចក្ដីថ្លៃថ្នូរ សេចក្ដីថ្លៃថ្នូរនាំឲ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិនាំឲ្យបានធម៌ ធម៌ដឹកនាំឲ្យបានសេចក្ដីសុខ ។

វិជ្ជាមានពីរយ៉ាង គឺសស្ត្រវិជ្ជា នឹងសាស្ត្រវិជ្ជា វិជ្ជាទាំងពីរយ៉ាងនេះគួរប្រតិបត្តិសិក្សារៀនឲ្យចេះដឹងទាំងអស់ វិជ្ជាទី ១ (សស្ត្រវិជ្ជា) គេតំរើនឡើងដើម្បីសើចលេងជាថុកកំប្លែង, វិជ្ជាទី ២ (សាស្ត្រវិជ្ជា) បុគ្គលគួរគោរពគ្រប់កាលទាំងពួង ។

ក្នុងអតីតកាល មាននគរមួយឈ្មោះបាដលីបុត្រស្ថិតនៅក្បែរស្ទឹងគង្គា ។ ព្រះបាទសុទសនៈ ទ្រង់ប្រកបដោយស្វាមិគុណគ្រប់ប្រការ ស្តេចគ្រប់គ្រងនគរនោះ ។

សម័យមួយទ្រង់បានព្រះសណ្ដាប់សុភាសិត ដែលអ្នកប្រាជ្ញបានពោលទុក មានសេចក្ដីដូចតទៅនេះ ;

សាស្ត្រវិជ្ជា ជាគ្រឿងកាត់បង់នូវសេចក្ដីសង្ស័យជាអនេក ជាគ្រឿងបើកបង្ហាញនូវអាថ៌កំបាំង នឹងជាភ្នែកសម្រាប់មើលសព្វសារពើការណ៍ទាំងឡាយ អ្នកណាមិនមានសាស្ត្រវិជ្ជា អ្នកនោះទុកដូចជាមនុស្សខ្វាក់ ។

## អាននិងពន្យល់ពាក្យ

នរជន = (អ. ថ. នៈ រៈ ជន) មនុស្ស. ជន ។

វិន័យ = (អ. ជ. វិនៃ) ការដឹកនាំទៅរកផ្លូវល្អ ។

នរបតី = (អ. ថ. នៈ រៈ ប៉ៈ ដី បូនរប់បដី) ម្ចាស់នៃពួកមនុស្ស (ក្សត្រិយ៍ទ្រង់រាជ្យ) ។

សស្ត្រវិជ្ជា– (អ. ថ. ស័សស្ត្រៈ វិជា) វិជ្ជាកសាង ឬប្រើអាវុធសម្រាប់ប្រហារគ្នាទៅមក ។

សាស្ត្រវិជ្ជា- (អ.ថ. សាសស្ត្រៈវិជ្ជា) ការចេះដឹង ក្បួន ខ្នាត គម្ពីរដីកា ច្បាប់សម្រាប់ប្រតិបត្តិ ឱ្យកើតសេចក្ដីសុខក្សេមក្សាន្ត ឬសេចក្ដីចំរើនលោក ។

បាដលីបុត្រ– (អថ: ប៉ាដ: លីបុត្រ) ជាឈ្មោះនគរមួយក្នុងអតីតកាល ។

សព្វសារពើ= (អ.ថ.សរ.) ហេតុឬដំណើរការអ្វី ៗ ទាំងអស់ ។

ពាក្យសួរ= វិជ្ជាមានប្រយោជន៍ដូចម្ដេចខ្លះ? វិជ្ជាមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? បុគ្គលគួរសិក្សារៀនឲ្យចេះដឹងវិជ្ជាទាំងពីរយ៉ាងនេះឬទេ? វិជ្ជាទាំងពីរយ៉ាងនេះវិជ្ជាណាដែលប្រសើរជាង? ។

## ប្រយោជន៍នៃវិជ្ជា (គ)

កាលព្រះរាជាអង្គនោះ ទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ក៏ទ្រង់ព្រួយតានតឹងព្រះរាជហឫទ័យ ចំពោះព្រះរាជបុត្ររបស់ព្រះអង្គដែលមិនទាន់សិក្សាសាស្ត្រវិជ្ជាទាំងឡាយ ព្រមទាំងប្រព្រឹត្តក្នុងផ្លូវខុសគន្លងធម៌ដោយសេចក្ដីប្រមាទ ទើបទ្រង់ព្រះដម្រិះដូច្នេះថា ៖

មានប្រយោជន៍អ្វី ចំពោះកូនដែលកើតហើយល្ងង់ផង, មិនប្រកក

ដោយធម៌ផង ដូចភ្នែកឈើមានប្រយោជន៍អ្វី ? បានត្រឹមតែឈើចាក់ដោតនាំឲ្យរំខានប៉ុណ្ណោះ ។

បណ្ដាកូន ៣ ពួក គឺកូនមិនទាន់កើតមួយពួក, កូនកើតហើយស្លាប់ទៅវិញមួយពួក នឹងកូនល្ងង់មួយពួក កូនពីរពួកខាងដើមជាកូនគាប់ប្រសើរ ពួកកូនទី ៣ មិនប្រសើរឡើយ ព្រោះថាកូនពីរពួកខាងដើម ធ្វើទុក្ខព្រួយតែម្ដងក៏អស់ហើយទៅ ឯពួកកូនទី ៣ ធ្វើទុក្ខមាតាបិតាគ្រប់ជំហានជើង ។

អ្នកណាកើតហើយនាំត្រកូលឲ្យចំរើនខ្ពង់ខ្ពស់ឡើង អ្នកនោះឈ្មោះថា កើត មែនទែនឬពេញជាកើតត្រឹមត្រូវ ។ កូនមានគុណគាប់តែម្នាក់ ជាកូនប្រសើរ កូនល្ងង់ពប់រយមិនប្រសើរទេ ដូចព្រះចន្ទតែមួយ-ដួងអាចកំចាត់ងងឹតអន្ធការបាន កង់តារាទាំងឡាយកំចាត់ងងឹតមិនបានឡើយ ។

## ពន្យល់ពាក្យ.–

ងងឹតអន្ធការ = ដែលងងិតសូន្យឈឹង ។

កង់តារា = ពួកផ្កាយ ។

ពាក្យសួរ .– ព្រះបាទសុខសនៈទ្រង់ព្រះជម្រិះថាដូចម្ដេច ?

កូនមានប៉ុន្មានពួក? កូនពួកណាគាប់ប្រសើរ? កូនពួកណាដែលមិនគាប់ប្រសើរ? ព្រោះអ្វី? អ្នកណាដែលកើតហើយឈ្មោះថាពេញថាជាកើតមែនទែន? ។ល។

---

អាទិកដ្ឋាន

## រៀនមើល – ហាត់ភាសា

អាទិត្យទី ១១.– អំពីរូបកាយមនុស្ស

### ក្បាល

នាម– ក្បាល, សក់, មុខ, ថ្ងាស, ភ្នែក, ច្រមុះ, មាត់, បបូរមាត់, ធ្មេញ ចង្កូម ថ្គាម អណ្តាត ចង្កា ពុកចង្កា ថ្ពាល់ កោមចិញ្ចើម ត្រចៀក ក ។

គុណនាម– មូល, សំប៉ែត, រាប, ខូង, ខ្ពស់, ខ្មៅ, ស, ពព្រុះ, ងងិត, ក្ងី, ស្រួច, ទាល, ធំ, តូច, ក្រាស់, ស្តើង, ថ្លោស, ធ្មារ, វែង, ខ្លី, រីង, ទន់ ។

កិរិយាសព្ទ– កាត់សក់, សិតសក់, លុបមុខ, លាងក្បាល, ផ្ទៀងត្រចៀកស្តាប់, ដុសធ្មេញ, ជូតថ្ពាល់, ហិតក្លិន, ភ្លក់រសជាតិអាហារ, កោរពុកមាត់ពុកចង្កា, កាល់ចិញ្ចើម ។

ហាត់ភាសា – ក្បាលមនុស្សរាងដូចម្ដេច ? នៅលើក្បាលមានអ្វី ? សក់មនុស្សចាស់យ៉ាងដូចម្ដេច ? ហៅថាអ្វី ? សក់មនុស្សក្មេងយ៉ាងដូចម្ដេច ? នៅសងខាងក្បាលមានអ្វី ? ត្រចៀកសម្រាប់ធ្វើអ្វី ? ក្បាលភ្ជាប់ទៅដងខ្លួននឹងអ្វី ។

យើងស្គាល់របស់ល្អអាក្រក់ដោយសារអ្វី ? នៅក្នុងមាត់មានអ្វីខ្លះ ? ។ល។ .....

ការហាត់សរសេរ – ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ ៖

ក្បាល, ភ្នែក, ច្រមុះ, ត្រចៀក

## បង្រៀនមើល

## អំពីខ្លួនមនុស្ស

( សៀវភៅវត្ថុស្វាធ្យាយន៍ អាទិកដ្ឋានទំព័រ ៥ ) ។

អានពាក្យ – អដ្ឋិសន្ធិលិក = អ័តបិសន់ធះលិកៈ ។

អវយវៈ = អៈ វៈ យៈ វៈ ។

តម្រូវពាក្យ – រលា = លលាដ៍ ។ រន់ = រន្ធ ។

សុតតែ = សុទ្ធតែ ។

ហាត់ភាសា - ខ្លួនមនុស្សមានប៉ុន្មានចំណែក? គឺអ្វីខ្លះ? នៅក្បាលចំណែកខាងមុខមានអ្វីខ្លះ? ច្រមុះបារាំងយ៉ាងដូចម្ដេច? ចុះច្រមុះខ្មែរយ៉ាងដូចម្ដេច? មនុស្សកខ្លីគេហៅថាអ្វី? ចុះមនុស្សកវែង? ឆ្អឹងលលាដ៍ក្បាលរាងដូចម្ដេច? មានសណ្ឋានដូចអ្វី? មាត់យើងមានថ្គាមប៉ុន្មាន? នៅលើថ្គាមមានអ្វី ថ្គាមលើនិងថ្គាមក្រោមខុសគ្នាដូចម្ដេច?

ៗ ល ៗ

## សរសេរតាមសូត្រ

### ខ្លួនមនុស្ស

ខ្លួនមនុស្សមានបីចំណែក គឺក្បាល ដងខ្លួននិងដៃជើង ក្បាលរាងមូល នៅលើក្បាលមានសក់ សក់ក្មេងខ្មៅ សក់មនុស្សចាស់សគឺសក់ស្កូវ ។ នៅមុខមានភ្នែកពីរសម្រាប់មើល មនុស្សក្មេងភ្នែកភ្លឺមើលឃើញច្បាស់ ។ ច្រមុះមានរន្ធពីរសម្រាប់ដកដង្ហើម ។ ខាងក្រោមច្រមុះមានមាត់និងបបូរមាត់ពីរ ។ កាលណាគេហាមាត់ គេឃើញធ្មេញនិងអណ្ដាត ។ អណ្ដាតសម្រាប់និយាយ ។ ខាងក្រោមមាត់មានចង្កា នៅសងខាងចង្កាមានថ្ពាល់ ។ មនុស្សប្រុសមានរោមដុះនៅបបូរមាត់លើនិងថ្ពាល់ហើយនិងចង្កា គឺជាពុកមាត់ពុកចង្កា ។

## តែងសេចក្តី

សរសេរពាក្យពិបាក – រន្ធ – បបូរមាត់ – ថ្ពាល់ – អណ្តាត – ថ្គាម – ធ្មេញ – ចង្កា ។

អ្នកបានពិនិត្យរូបរាងកាយនៃមិត្តសំឡាញ់របស់អ្នក ចូរអធិប្បាយអំពីរូបរាងកាយនៃមិត្តសំឡាញ់របស់អ្នកនោះ

ដំណើរតែង

សេចក្តីផ្តើម – មិត្តសំឡាញ់អ្នកឈ្មោះអ្វី? រៀនសូត្រនៅឯណា ?

សេចក្តីរៀបរាប់ - អំពីក្បាល - មុខ-មាត់ ដៃជើង-ដងខ្លួនកំពស់ ។

សេចក្តីបញ្ចប់ – អំពីកិរិយាមារយាទ – សំលៀកបំពាក់នៃមិត្តសំឡាញ់នោះ និងសេចក្តីយល់ឃើញរបស់អ្នក ។

## អក្សរផ្ចង់

ខ ខ ខី ខិ ខ៊

ខឹងខុស ខុសខូច ខូចខាត ខកញ៉ាខ្ញុំខ្សឹកខ្សីខំ ។

# បង្រៀនពាក្យ - ហាត់ភាសា

អាទិត្យទី ៦ – អំពីដងខ្លួន

នាម – ទ្រូង ពោះ ផ្ចិត ខ្នង ចង្កេះ ត្រគាក ស្មា សួត បេះដូង ថ្លើម ប្រមាត់ ក្រពះបាយ ពោះវៀន ។

គុណនាម – ពើង ប៉ោង ផត ធំ ធ្លាយ កោង ស្វិត វែង ខ្លី ខ្ចឹង ក្រហម យឺត រីក ។

កិរិយាសព្ទ – ស្ទាបទ្រូង ឈឺពោះ រួយចង្កេះ កប់ចង្កេះ ស្រពន់ជើង-ដៃ ដកដង្ហើមចេញ-ចូល ឈាមរត់ ចុះស្មា ។

ហាត់ភាសា ឯណាដងខ្លួន ? ដែលហៅថាដងខ្លួនពីត្រឹមណា ទៅដល់ត្រឹមណា ? នៅដងខ្លួនមានអ្វីខ្លះ ? ទ្រូងនៅត្រង់ណា ? ពោះនៅត្រង់ណា ? នៅលើពោះមានអ្វី ? ខាងក្រោយដងខ្លួនហៅថាអ្វី ? ក្នុងទ្រូងមានអ្វី ? នៅក្នុងពោះមានអ្វី ? សួតសំរាប់ធ្វើអ្វី ? បេះដូងសម្រាប់ធ្វើអ្វី ? ។

ការហាត់សរសេរ – ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោម នេះ ៖

ក្បាលជាប់ទៅ . . . . . . នឹងក ។ ចំណែកខាងលើដងខ្លួនមាន . . . . ចំណែកខាងក្រោមមាន . . ខាងក្រោយមាន . . . . ។ ក្នុងទ្រូងមាន . . . . សម្រាប់ដកដង្ហើមមាន . . . . . សម្រាប់បន្ហូរឈាម ។ ក្នុងពោះមាន . . . . . នឹង . . . . ដែលជាប្រដាប់សម្រាប់រំលាយអាហារ ។

## បង្រៀន - មើល

### អដ្ឋិសង្ខលិក - ដងខ្លួន

សៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ៦

## តែងសេចក្តី

ចូរអធិប្បាយអំពីមិត្តសំឡាញ់អ្នកម្នាក់ រត់ទាត់សីក្បាត់ជើងដួលបាក់ដៃម្ខាង អ្នកបានពិនិត្យឃើញឆ្អឹងនោះដូចម្តេចខ្លះ ? រួចគ្រូពេទ្យបានធ្វើដូចម្តេចខ្លះ ?

យោបល់របស់អ្នកយល់ឃើញដូចម្តេច ? ។

## សរសេរតាមសូត្រ

### អំពីដងខ្លួន

ក្បាលតភ្ជាប់ទៅដងខ្លួននឹងក ។ ចំណែកខាងលើដងខ្លួនមានទ្រូង ខាងក្រោមមានពោះ ខាងក្រោយមានខ្នង ។ ក្នុងទ្រូងមានសួតសម្រាប់ដកដង្ហើម មានបេះដូងសម្រាប់បង្ហូរឈាម មានថ្លើមសម្រាប់បញ្ចេញទឹកប្រមាត់ ។ ក្នុងពោះមានក្រពះបាយនឹងពោះវៀន ដែលជាគ្រឿងប្រដាប់សម្រាប់រំលាយអាហារ ខាងក្រោមមានប្លោកនោម សម្រាប់ទទួលទឹកនោមមកពីអង្គញ់ចង្កេះដែលនៅក្រោមខ្នង ។

សរសេរពាក្យពិបាក - ក = ពោះ - បេះដូង - បង្ហូរ - សម្រាប់ឬសំរាប់ - បញ្ចេញ - ប្លោក - អង្គញ់ - ចង្កេះ ។

## អក្សរផ្ចង់

ខ ឧ ឱ ឲ ឳ

គេខុសកុំអាលអរ គេសាទរកុំអាលអួត

## បង្រៀនពាក្យ - ហាត់ភាសា

អាទិត្យទី ៣ ដៃជើង (អវយវៈលើ)

នាម.— ដើមដៃ កែងដៃ កំភួនដៃ កដៃ ដៃ បាតដៃ ខ្នងដៃ ម្រាមដៃ ចង្អុលដៃ ម្រាមកណ្ដាល នាងដៃ កូនដៃ

គុណនាម.— តូច ធំ វែង ខ្លី ស្រួច ស្តួច រឹង សំប៉ែត ស្ដាំ ឆ្វេង ៗ

កិរិយាសព្ទ.— លាដៃ បត់ដៃ លាតដៃ ចាប់ដៃ កាន់ដៃ លើកដៃ ឱបដៃ ក្រពត់ដៃ ៗ

ហាត់ភាសា.— យើងមានដៃប៉ុន្មាន? ឯណាដៃស្ដាំ ឯណាដៃឆ្វេង? ដៃនីមួយៗ មានប៉ុន្មានបំណែក? ដើមដៃនឹងកំភួនដៃខណ្ឌគ្នានឹងអ្វី? ដៃនីមួយៗ មានម្រាមប៉ុន្មាន? ម្រាមទាំងប្រាំនេះឈ្មោះដូចគ្នាឬទេ? អ្នកស្គាល់ឈ្មោះម្រាមដៃទាំងនេះឬទេ? ដៃសម្រាប់ធ្វើអ្វី? មេដៃទល់នឹងម្រាមឯទៀតឬទេ? កូនដៃសម្រាប់ធ្វើអ្វី? ៗ

## បង្រៀនមើល

អដ្ឋិសង្ខលិកៈ (អវយវៈលើ)

សៀវភៅដដែលទំព័រ ទី ៨

កែតម្រូវពាក្យ ៖ ផ្ជាប់ = ភ្ជាប់ ។ កំបិត = កាំបិត ។ បាតដៃ ។ ប្រសប = ប្រសព្វ ( ប្រសព្វភ្ជាប់គ្នា ប្រសព្វមុខគ្នា ) ។ ខ្នង = ស្នង ( ស្នងជើង - ខ្នងត្រី ) ។

## សរសេរតាមសូត្រ

### អំពីដៃជើង ( អវយវៈលើ )

មនុស្សយើងមានដៃពីរ គឺដៃស្តាំនិងដៃឆ្វេង ។ ដៃជាប់ទៅដងខ្លួននិងស្មា ហើយនិងឆ្អឹងដងកាំបិត ។ ដៃមានបីចំណែក គឺដើមដៃ កំភួនដៃ និងគ្ជូដៃ ។ ដើមដៃជាប់ទៅកំភួនដៃនិងកែងដៃ ។ គ្ជូដៃមានម្រាមប្រាំ គឺមេដៃចង្អុលដៃ ម្រាមកណ្តាល នាងដៃ ហើយនិងកូនដៃ ។ គ្ជូដៃមានខ្នងដៃនិងបាតដៃនៅចុងម្រាមដៃនិមួយ ៗ មានក្រចក ។ ដៃសម្រាប់ចាប់និងកាន់របស់ទាំងឡាយ ។

សរសេរពាក្យពិបាក - កាំបិត - ម្រាមប្រាំ - គ្ជូដៃ = របស់ ។

## តែងសេចក្តី

### ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ ៖

ដៃ , ម្រាមដៃ , កំភួនដៃ , នាងដៃ , កែងដៃ

## បង្រៀនពាក្យ – ហាត់ភាសា

### ដៃជើង ( អវិយវៈ ក្រោម )

នាម .– ជើង ក្ដៅ ជង្គង់ កំភួនជើង ស្នងជើង កជើង កែង គោរម្រាមជើង បាតជើង កែងជើង តួជើង ។

គុណនាម.– ធំ មាំ ខ្លាំង ខ្សោយ រហ័ស យឺត លឿន វែង ខ្លី រាប ខ្ពង ធ្ងន់ ស្រាល

កិរិយាសព្ទ.– ដើរ រត់ លោត ផ្លោះ ទាត់ ធាក់ អង្គុយ លុតជង្គង់ ដេក ឈរ ក្រោក ។

ហាត់ភាសា .– ( សុំឲ្យសួរបំបែកប្រាជ្ញាសិស្សដូចមុន )

ការហាត់សរសេរ .– ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖ ជើងសម្រាប់ធ្វើអ្វី ? ជើងនីមួយ ៗ មានប៉ុន្មានចំណែក ? គឺអ្វីខ្លះ ? ស្នងជើងនៅត្រង់ណា ? ជើងជាប់ទៅដងខ្លួននឹងអ្វី ? កន្លែងដែលចំណូ ក្ដៅនឹងកំភួនជើងហៅថាអ្វី ? ។

## បង្រៀនមើល

### អដ្ឋិសង្ខលិកៈ អវិយវៈក្រោម ( គ )

សៀវភៅដដែលទំព័រ៨ - ៩

## សរសេរតាមសូត្រ

### អវិយវៈ ក្រោម

យើងមានជើងពីរសម្រាប់ដើររត់លោត ៗ ជើងនិមួយ ៗ មានភ្លៅមួយ មានស្នងនៅខាងមុខ កំភួនជើងនៅខាងក្រោយហើយនឹងគូជើងនៅខាងចុង ។ ភ្លៅជាប់ទៅស្នងនឹងជង្គង់ហើយនឹងក្បាលជង្គង់ ។ ស្នងជាប់ទៅគូជើងនឹងកជើងហើយនឹងភ្នែកគោរ ។ គូជើងមានម្រាមប្រាំដូចជាគូដៃដែរ ប៉ុន្តែម្រាមជើងខ្លីជាងម្រាមដៃ ហើយចាប់កាន់អ្វីក៏ពុំបានផង ។

សរសេរពាក្យពីបាក.— ពីរ - ភ្លៅ - ជង្គង់ - ស្នង ភ្នែកគោរ-គូ-ក ៗ

## តែងសេចក្ដី

ជីតាអ្នកចាស់ជរា ចូរអ្នកអធិប្បាយអំពីកិច្ចធុរៈ ដែលអ្នកបានធ្វើបានគោរពដល់ជីតាអ្នកនោះតើដូចម្ដេចខ្លះ ? ៗ

### សេចក្ដីអធិប្បាយជាគំរូ

សូមមើលទស្សនាវដ្ដីទី ៣ លេខ ៥ ទំព័រ ២៦

អាទិត្យទី ៤ ·–

## សូមសាបស្រៀនពីដើមឡើងវិញ

## បរិច្ឆណាដ្ឋាន

អាទិត្យទី១– ច្បាប់បញ្ញត្តិអំពីកាប់គាស់ព្រៃ

( សុំយកតាមសៀវភៅវត្ថុសាធ្យាយន៍អាទិកដ្ឋាន ទំព័រ ១០៤ )

នាម– ច្បាប់ (បញ្ញត្តិ) ព្រៃរក្សាទុក បណ្ដាក្រស្ដ ព្រៃបំរុងទុក ក្រសួងព្រៃភោគសម្បត្តិ, ពន្ធ.

គុណនាម – អន្តរាយ, វិនាស, ហិន, ហិនហោច, ចំរើន ។

កិរិយា– បញ្ញត្ត, កាប់គាស់, រក្សា, ថែរក្សា, បំរុង, ទុកបំរុង, កាន់កាប់, ដេញ, ដេញថ្លៃ, ស្ម័គ្រចិត្ត, ព្រមព្រៀង, ការពារ, សំរាំង, មានអំណាច, ប្រើប្រាស, ត្រូវការ, បង់ពន្ធ, អនុញ្ញាត ។

ភាសា – តាមបញ្ញត្តិច្បាប់ព្រៃឈើចែកជាប៉ុន្មានយ៉ាង ? ហៅថាព្រៃអ្វីខ្លះ ? រាជការប្រគល់ឲ្យក្រសួងណា ឲ្យកាន់កាប់រក្សាព្រៃឈើ ប្រយោជន៍អ្វីបានជាគេឲ្យរក្សាព្រៃឈើ ? អ្នកនៅជិតព្រៃរក្សាទុកនោះ រាជការបើកអំណាចឲ្យធ្វើបានដូចម្ដេចខ្លះ ? ឯព្រៃណាដែលបំរុងទុកនោះ ត្រូវបានអំណាចធ្វើដូចម្ដេចខ្លះ ? រាជការក្រសួងមេព្រៃបើកអំណាចឲ្យ កាប់បានយ៉ាងណា ?

## អាទិត្យទី២– បញ្ញត្តិកាប់រានព្រៃ

(សុំយកតាមក្នុងសៀវភៅវត្ថុស្ថាធ្យាយន៍ ទំព័រ ១០៧)

នាម – កិច្ច, ធុរៈ, ចង្កេះភ្នំ, ខ្នងភ្នំ, ជើងភ្នំ, ដើមស្រល់, វល្លិ៍, កៅស៊ូ, ជ័រ ។

គុណនាម– រាបស្មើ (កុំច្រឡំនឹងរៀប រៀបចំ) រលីងរោត (កុំច្រឡំនឹងរោទ) ទំនាប ទាប ។

កិរិយា– រានព្រៃ (កុំច្រឡំនឹងរៀនអក្សរ) ផ្ដួល (ដួល) រំលំ ឃ្លាំល្បាត យាមល្បាត ។

ភាសា– ពីព្រោះអ្វីបានជាមានបញ្ញត្តិថា បើកាប់ឈើក្នុងព្រៃត្រូវឲ្យទុកខ្លះ? មួយទៀតថាបើនឹងកាប់ ត្រូវកាប់ឲ្យរាបស្មើនឹងដីតើពីព្រោះអ្វី? បើទីកន្លែងណាជាទីចោតឬមានច្រើន គេត្រូវកាប់យ៉ាងណា? ពីព្រោះអ្វី? បើកាប់ឈើធំ តើត្រូវកាប់យ៉ាងណា? ពីព្រោះអ្វី?

## អាទិត្យទី៣– គ្រឿងឧបករណ៍សំរាប់រានព្រៃ

នាម– កាំភ្លើង ស្នា ធ្នូ (ធនូ) ព្រួញ អន្ទាក់ ខ្នា (អន្ទាក់មាន (ព្រួញ)) ទ្រនិចស្នា ដៃស្នា ស្នូកាំភ្លើង ត្រែកាំភ្លើង កៃកាំភ្លើង បន្ទោះស្នា ប្រតឹង លប អន្ទាក់ កាំភ្លោះ ។

គុណនាម– កាំភ្លើងខ្លីង ស្នាធ្ងន់ ដៃត្រង់ គ្រាប់រហ័ស ស្នូកាំភ្លើងវែង ជង្ខ្នារកោង ។

កិរិយា - បាញ់ឈ្លូស ដំរង់ព្រួញ ពត់ព្រួញ ដំឡើងស្នា លោះ កៃ ដាក់គ្រាប់ លាបជ័រ លើកសត្វ ដេញទន្សាយ ដាក់អង់ ធ្លុះ ខ្វែកគ្រោក ។

ភាសា ព្រានដែលរកស៊ីទាក់ចាប ហៅដូចម្ដេច? (ហ្មចាប) ទេសាទបករណ៍អ្វីខ្លះទៀតដែលអ្នកស្គាល់? គេធ្វើដូចម្ដេចនឹងចាប់ទន្សាយបាន? បណ្ដាពួកទេសាទ ទេសាទអ្វីដែលមានប្រយោជន៍ធំ?

(ទេសាទត្រី)

អាទិត្យទី ៤ -

## សត្វព្រៃដែលគេបាញ់

នាម - ដំរី, រមាស, ប្រើស, ទ្រាយ, ទន្សោង, ខ្លា, ជ្រូក, ឈ្លូស, ទន្សាយ, ក្ដាន់, រមាំង, គោព្រៃ, ទុង, ត្រដក់, រនាល, សាច, ក្ងក, កុយ, ស្វែង, ស្វ្សែក, ស្វាប ។

គុណនាម - ធំ, ធាត់, សាហាវ, ស្គម, កាច, ស្លូត, ថោក ថ្លៃ ។

**រៀនមើល - សរសេរ**

អាទិត្យទី ១–

## ច្បាប់បញ្ញត្តិអំពីកាប់គាស់ព្រៃ

សៀវភៅវត្ថុស្វាធ្យាយន៍ទំព័រ ១០៤

អាទិត្យទី២ – បញ្ញត្តិកាប់រានព្រៃ

(សៀវភៅដដែលទំព័រ ១០៧ )

អាទិត្យទី៣ – មេរៀនសត្វព្រៃ

នៅក្នុងព្រៃធំៗ មានសត្វព្រៃជាច្រើន ។ សត្វដែលកាចសាហាវជាងគេគឺខ្លា វាស៊ីសាច់ឆៅជាអាហារ ។ សត្វដំរីធំជាងគេទាំងអស់ ប៉ុន្តែមិនកាចប៉ុន្មានទេ ។ គេយកមកប្រើបានដូចគោក្របីដែរ ។

ជ្រូកព្រៃជាសត្វចង្រៃ, វាស៊ីដំណាំយើង ។ ខ្លាឃ្មុំស៊ីឃ្មុំជាអាហារ ប្រើស ក្តាន់ ឈ្លូស ទន្សាយ ស៊ីស្មៅទាំងអស់ សាច់វាមានរសជាតិណាស់ សំពោចច្រើននៅក្នុងគុម្ពឫស្សី ហើយចេញលួចចាប់មាន់ស៊ីវេលាយប់ ។

( សុំបង្រៀនសិស្សឲ្យស្គាល់សត្វទាំងអស់នេះ ដូច្នេះគ្រូរកផ្ទាំងគំនូរដែលមានសត្វព្រៃ មកបង្ហាញសិស្សឲ្យឃើញផង ពីព្រោះកុមារខ្លះមិនស្គាល់សត្វទាំងនោះទេ ។

## អាទិត្យទី៤– សត្វស្លាបព្រៃ

ត្រដក់ធំជាងគេតាំងអស់ ។ រាជការបានហាមប្រាមមិនឲ្យបាញ់ ទុង រនាល ត្រដក់ទេ ។ ក្រៀលច្រើនយំពេលថ្ងៃត្រង់ ។ នៅក្នុងបឹងមានប្រភេទនឹងទោមច្រើនណាស់ ។ ស្មោញ ក្អែកទឹក រកស៊ីក្នុងបឹងចាប់ត្រីស៊ីជាអាហារ ។ ខ្វែករកស៊ីតែវេលាយប់ ជាសត្វស៊ីត្រីដែរ ។ បចាតខ្លួនតូចពណ៌ខៀវស្រងាត់ ។

អកច្រើនតែយំពេលថ្ងៃត្រង់ ។ ខ្លែងជាសត្វចង្រៃវាចាបកូនមាន់ ទីទុយជាសត្វមានប្រយោជន៍ណាស់ វាចាប់សត្វចង្រៃស៊ី ដូចជាក្ដាមជាដើម ដែលវាកាត់ស្រូវយើង ។ មានមនុស្សច្រើនចូលចិត្តបរិភោគសាច់មាន់ទោ ។ ពពូលពណ៌ខៀវវាស៊ីផ្លែពោធិនឹងផ្លែជ្រៃ ។ លលករកស៊ីដោយវាលស្រែ ។

---

កុមារដ្ឋាន

## រៀនពាក្យ - ហាត់ភាសា

### អាទិត្យទី ១.– អំពីផ្ទះ

ផ្ទះរោង, រានផ្ទះខ្មែរ ផ្ទះគៀម ផ្ទះថ្ម ផ្ទះឈើ ។ ផ្ទះឥដ្ឋទំនើប ចាស់

មាំ ជាប់ ទូលាយ បង្អៀត គ្រាំគ្រា ។ សង់ផ្ទះ រុះរើនៅជួសជុល គួរផែនទី វាស់ខ្នាត ។

កាសា.- ឪពុកម្ដាយអ្នកមានទីលំនៅ ៗ ផ្ទះអ្វី ? ផ្ទះឪពុកម្ដាយអ្នកថ្មីឬចាស់ ? ផ្ទះនោះជាលំនៅទូលាយឬបង្អៀត ? ខ្ពស់ឬទាប ? ផ្ទះរោងនឹងផ្ទះខ្មែរមានទ្រង់ទ្រាយដូចគ្នាឬខុសគ្នា ? អ្នកដែលបានឃើញគេសង់ផ្ទះឬទេ ?

## ពាក្យត្រូវរៀនក្នុងកំឡុងអាទិត្យទី ១

ខ្ទម, រោង, កុដិ, ព្រះវិហារ, ប្រាសាទ, វាំង (ដំណាក់ស្ដេច) ព្រះពន្លា (រោងឬបាំងចំណតនៃស្ដេច) សាលា (ផ្ទះជាទីប្រជុំជន) ឬផ្ទះសំរាប់សំណាក់) ផ្ទះស្លឹក, ផ្ទះស្បូវ, ផ្ទះក្បឿង, ផ្ទះក្ដារ, ផ្ទះឥដ្ឋឬថ្ម, ប្រាង្គ មណ្ឌប (អានថាមនដប់គឺប្រាសាទតូច ៗ មានកំពូលដូចមកុដ) ។

ខ្ទមតែកតោក, រោងធំល្វឹង, ក្រញឹប, ព្រះវិហារស្រឡះ ស្រអាប ខ្ពស់ ទាប, ប្រាសាទឆើត ឆាយ, វាំងចាស់, វាំងមាំមួន ។

ឈប់សំរាក, ប្រជុំគ្នា, បត, ជ្រក, ប្រថាប់, សង់រោង, សាងព្រះវិហារ, កសាងសាលា, ឡើងផ្ទះ, ចូលរោង, សម្ពោធ ឬសម្ពោធន៍ (ចូលឬឡើងផ្ទះ) ។

អាទិត្យទី ២.- គ្រឿងតុតាំង

ទូ, តុ, គ្រែ, កៅអី, ជើងម៉ា, ជើងតាំង, តុរៀបគ្រឿងសំអាង

កញ្ចក់, ហិប, ក៉លីស, ពូក, ខ្នើយ, កន្ទេល, ព្រំ, កំរាល នាឡិកា យោល គោម ក្ដារខៀន រនាំង វាំងនន មុខទ្វារ, មុខគ្រែ, ឡប់ឡែ, កាំយបង្អួចទ្វារ ៗ

តុរលោង, គ្រែខ្ពស់, ពូកទន់, កំរាលល្អ រនាំងក្រហម ៗ ខាត់ ខូ, ជូតតុ, រៀបគ្រែ, រើគ្រែ អង្គុយលើកៅអី, ឆ្លុះកញ្ចក់, ក្រាលកន្ទេល, ឆ្លៀងម៉ោង, ដាក់នាឡិកា, ឫនាលិកា, ដាក់រនាំង, លើករនាំង, ចាំង-ទ្វារ, ថែទាំ, ជូតជុស, សំអាត ៗ

អាទិត្យទី ៣.- គ្រឿងសង់ផ្ទះ ឈើប្រើការក្នុងគ្រឿងផ្ទះ

សរសរ, ជញ្ជាំង, កំរាល, បន្ទប់, ល្វែងចន្ទ (ល្វែងកណ្ដាល) ល្វែងទទួលភ្ញៀវ, ល្វែងដេក, បន្ទប់គ្រឿងសំអាង, ចាំងសាប, រានហាល, បន្ទប់ទឹក, ផ្ទះបាយ ៗ

ឈើជាប់, ផ្ចឹក, សុក្រំ, រាំងភ្នំ, កកោះ, គ្រញូង, នាងនួន, គគីរ, ពពេល ៗ

ឈើទាល, ត្រាច, ខ្ទង តែ្បង, ស្រឡៅ, ខ្វាវ, ឫស្សី, ផ្ដៅ ៗ

សរសរមូល, គ្រង់, វែង, ខ្លី, ជញ្ជាំងទាប, ស្រោង, ស្រអិប, កំរាល, រលោង, ស្មើ, ជាប់, ស៊ុយ, ឈើជាប់, រឹង, ទន់ ៗ

លើកសរសរ, ក្រាលក្ដារ, រនាប, ឥដ្ឋ ៗ ទទួលភ្ញៀវ រៀបចំផ្ទះ, តាក់តែង, លាបថ្នាំ, ទល់, ជ្រែង ៗ

អានិត្យទី ៤.–

ជាងឈើ, ជាងដែក, ជាងបាយអ, ជាងលាបថ្នាំ ។ ជាងប្រសប់, ឆ្លាត, ស្អាត, ហ្មត់ចត់, ទឹងទឹង, ល្អ, ខ្ជិល ។ សិតសារស,

ឈូស, ចាំង, ដំរង់, ស្ទង់, ភ្ជិត, ផ្គុំ, ការ, កាត់, ដាប់, ពោះ, ទម្លុះ, ខួង, ប្រហក់, ត្រាំ, លាប, តួរ ។

## រៀនមើល – ហាត់សរសេរ

អានិត្យទី ១.– អំពីទីលំនៅ ផ្ទះខ្មែរ

(សុំមើលក្នុងសៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១០៦ ។

អានិត្យទី ២.– ភូមិខ្ញុំ

(វិជ្ជាខេមរៈ កុមារដ្ឋានទំព័រ ១០៨)

អានិត្យទី ៣.– ផ្លូវទៅភូមិខ្ញុំ

(សៀវភៅដដែលទំព័រ ១០៩)

អានិត្យទី ៤.– ក្រុមជាងសង់ផ្ទះ

(បរិវត្ត. ទំព័រ ៣៤)

កិច្ចដែលរៀនមើលសុំគ្រូធ្វើដូចរបៀបខាងក្រោមនេះ ៖

១.- សុំបង្រៀនឲ្យចេះមើលប្រាកដគឺមើលឲ្យច្បាស់ ហើយឲ្យត្រូវឃ្លាផង ទើបគេស្តាប់សេចក្តីបាន ។

២.- សុំឲ្យពន្យល់ពាក្យ ហើយឲ្យសិស្សចេះពន្យល់ពាក្យនោះវិញផង ។

៣.- ត្រូវឲ្យសិស្សប្រយ័ត្នគ្រប់គ្នានឹងមើលហើយនឹងពន្យល់ ។

៤.- សុំតែងពាក្យសួរតាមសេចក្តីមើលឲ្យសិស្សប្រុងឆ្លើយគ្រប់គ្នា ។

## តែងសេចក្តី
### សម្រាប់
## ប្រឋមភូមិបំពេញវិជ្ជា

កម្មវិធីសម្រាប់ខែ.— លិខិត

សេចក្តីលំនាំ— លិខិតជាការសន្ទនាគ្នាជាលាយលក្ខណ៍អក្សរជាមួយនឹងជនដែលនៅឃ្លាតពីខ្លួន ។

លិខិតមានបីបែបគឺ ៖

១- លិខិតស្និទ្ធស្នាលឬវង់ក្រុមគ្រួសារ គឺពួកលិខិតដែលគេសរសេរទៅកាន់ពួកក្រុមញាតិឬទៅមិត្តភក្តិ ។ លិខិតនេះត្រូវសរសេរឲ្យងាយយល់ហើយដោយផ្ចិតផ្ចង់ផង ។

២- លិខិតដែលគេសរសេរទៅកាន់ឯកជន ឬទៅកាន់អ្នកជំនួញក្នុងកិច្ចរកស៊ីធ្វើការ ។ គេត្រូវសរសេរលិខិតពួកនេះឲ្យបានច្បាស់លាស់ ហើយឲ្យមានសេចក្ដីខ្លី ។

៣- ពាក្យ គឺជាលិខិតមួយបែបដែលគេសរសេរទៅកាន់ រាជការ ដើម្បីសុំកន្លែង ឬសុំអនុគ្រោះអ្វីមួយ ។

សំបុត្រទាំងឡាយតែងមាន ៖

១- ដើមសំបុត្រ គឺត្រូវដាក់ទីកន្លែង កាលបរិច្ឆេទនិងឋានន្តរសក្តិអ្នកទទួលលិខិត)

២- តួសំបុត្រ

៣- សេចក្ដីបញ្ចប់និងហត្ថលេខា

របៀបដាក់ដើមសំបុត្រនិងសេចក្ដីបញ្ចប់

១- សំបុត្ររវាងក្រុមគ្រួសារ ឬសំបុត្រស្និទ្ធស្នាល

សូមក្រាបប្រណិប័តន៍ លោកតា លោកយាយ

សូមបានជ្រាប ។

... ... ... ... ... ... ... ... ... ... ... ... ... ...

សេចក្ដីគួរពុំគួរសូមបានអភ័យទោស

ហត្ថលេខា

សូមប្រណិប័តន៍លោកឪពុកអ្នកម្ដាយ

សូមបានជ្រាប ៗ

.. .. .. .. .. .. .. .. .. .. .. .. .. .. .. .. .. ..

សេចក្ដីគួរពុំគួរសូមបានអភ័យទោស

ហត្ថលេខា

សូមជំរាបមកលោកពូអ្នកមីង

សូមជ្រាប ៗ

ជំរាបមកអ្នកបង

ជាដំណឹង ៗ

ប្រាប់មកប្អូន

ឲ្យបានដឹង ៗ

មកដល់សំឡាញ់

ឲ្យបានដឹង ៗ

មកដល់ "សុវណ្ណ" ជាកល្យាណមិត្ត ឬជាមហាមិត្ត ៗ

២– ពាក្យផ្សេង ៗ

ក– បុរសធ្វើថ្វាយព្រះកជាអម្ចាស់ផែនដី ឬព្រះអគ្គមហេសី

សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

.. .. .. .. .. .. .. .. .. .. .. .. .. .. .. ..

គួរពុំគួរសូមទ្រង់ព្រះករុណាប្រោស

សូមព្រះរាជទានក្រាបបង្គំទូលនៅថ្ងៃ.... ខែ..... គ.ស. ១៩៥៣

ទូលព្រះបង្គំជាខ្ញុំឈ្មោះ .......

ហត្ថលេខា

ខ– បុរសធ្វើថ្វាយក្សត្រធំទ្រង់យសជាសម្តេច

សូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូលទ្រង់ព្រះករុណាពិសេស

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

.. .. .. .. .. .. .. .. .. .. .. .. .. .. .. ..

គួរពុំគួរសូមទ្រង់ព្រះករុណាប្រោស

ទូលបង្គំជាខ្ញុំឈ្មោះ........

ហត្ថលេខា

គ– បុរសធ្វើថ្វាយក្សត្រទីព្រះអង្គម្ចាស់ ។

សូមទ្រង់មេត្តាប្រោស

សូមក្រាបបង្គំទូល សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

...................................................

គួរពុំគួរសូមទ្រង់ព្រះករុណាប្រោស

ទូលបង្គំជាខ្ញុំឈ្មោះ ..........

ឃ- បុរសធ្វើថ្វាយក្សត្រីអ្នកអង្គម្ចាស់

សូមមេត្តាប្រោស ក្រាបទូលសូមទ្រង់ជ្រាប ។

...................................................

គួរពុំគួរសូមទ្រង់ប្រោស

ទូលបង្គំនាយ.........

សេចក្តីចំណាំ- បើស្ត្រីវិញក៏ដូចគ្នាដែរ ត្រង់របៀបខាងលើ នឹងសេចក្តីបញ្ចប់ ខុសតែត្រង់ថាជាខ្ញុំម្ចាស់វិញ ។

ង- ពាក្យទៅកាន់រដ្ឋមន្ត្រី

សូមបាននាយ..... ខ្ញុំប្របាទម្ចាស់ របររកទទួលទានធ្វើ..... ក្នុងឃុំ.. ..ស្រុក.....ខេត្ត.....

សូមក្រាបប្រណិប័តន៍ ជំរាបមកប្របាទម្ចាស់លោកអ្នកឧកញ៉ា (ងារ) រដ្ឋមន្ត្រីក្រសួងសិក្សាធិការ យុវជននិងសិល្បការ

សូមបានជ្រាប ។

... ... ... ... ... ... ... ... ... ... ... .. ..

គួរពុំគួរសូមទានអភ័យទោស

ហត្ថលេខា

ច- ពាក្យទៅកាន់មន្ត្រីសក្តិ ១០ ហ៊ូពាន់នឹង ៩ ហ៊ូពាន់

សូមទាននាយ...... ខ្ញុំប្របាទម្ចាស់ របររកទទួលទានធ្វើ...... ក្នុងឃុំ...... ស្រុក...... ខេត្ត......

សូមក្រាបប្រណិប័តន៍មកលោកអ្នកឧកញ៉ា សិរិវឌ្ឍរបវរសក្តិចៅហ្វាយក្រុងភ្នំពេញ

សូមទានជ្រាប ។

.. .. .. .. .. .. .. .. .. ... ... ... ... ... .. .. ..

គួរពុំគួរសូមទានអត់ទោស

ឆ- ពាក្យទៅកាន់មន្ត្រីសក្តិ ៧-៨ ហ៊ូពាន់

សូមទាននាយ... ខ្ញុំប្របាទ របររកទទួលទានធ្វើ... នៅឃុំ... ស្រុក... ខេត្ត... ប្រពន្ធឈ្មោះនាង... ។

សូមប្រណិប័តន៍មកអ្នកឧកញ៉ា (ម៉ារ) ក្ខុជួយខេត្តទី១ ខេត្តកំពង់ធំ

សូមជ្រាប ។

... .. .. ... .. ... .. ... .. .. .. .. .. .. .. ..

គួរពុំគួរសូមអភ័យទោស

ហត្ថលេខា

ង - ពាក្យទៅកាន់មន្ត្រីស័ក្តិ ៥ - ៦ ហ៊ូពាន់

សូមជូននាយ.... ប្រពន្ធឈ្មោះនាង.... ខ្ញុំប្របាទមានមុខការជាអ្នកធ្វើ.... នៅឃុំ.... ស្រុក.... ខេត្ត...

សូមប្រណិប័តន៍មកលោកព្រះ (ម៉ារ) បាទឡាត់ស្រុកស្តីទីចៅហ្វាយស្រុក....

សូមជ្រាប ។

... ... ... ... ... ... ... ... ... ... ... ... ... ... ...

គួរពុំគួរសូមអភ័យទោស

ហត្ថលេខា

ឈ - ពាក្យទៅកាន់មន្ត្រីស័ក្តិ ៣-៤ ហ៊ូពាន់

សូមជូននាយ... ខ្ញុំបាទនៅឃុំ... ស្រុក... ខេត្ត...

ជំរាបមកឃុន (ម៉ារ) ស្មៀនសាលាខេត្ត...

សូមជ្រាប ។

... ... ... ... ... ... ... ... ... ... ... ... ... ... ...

គួរពុំគួរសូមអភ័យទោស

ហត្ថលេខា

អាដិតកដ្ឋាន

# តែងសេចក្តី

រកគំនូរនឹងវត្ថុដែលត្រូវតែងមកបង្ហាញឲ្យសិស្សពិនិត្យមើល ហើយសួរណាទាំឲ្យឆ្លើយមាត់ទទេសិន ។

## អំពីដើមកប្បាស

សេចក្តីរំឭក មុនឲ្យសិស្សតែងសេចក្តីសូមលោកគ្រូពន្យល់ ហើយសួរបញ្ជាក់ដើម្បីឲ្យដឹងថាសិស្សយល់ច្បាស់ហើយឬនៅ ពីព្រោះកប្បាសពុំមែនមានដាំគ្រប់ភូមិភាគក្នុងប្រទេសកម្ពុជាទេ ដូច្នេះនៅស្រុកណាដែលគ្មានក្រុកជាតិនេះ សូមរកគំនូរមកបង្ហាញឲ្យសិស្សស្គាល់ប្រាកដផង ស្រុកដែលសម្បូណ៌ ឲ្យយកដើមផ្លែគ្រាប់សំឡីនឹងអំបោះមកបង្ហាញសិស្ស ពិតមែនជាផុតកម្ដាយក៏បានដាំតែក៏ពុំដែលបានពិនិត្យដោយហ្មត់ចត់ទេ ។ ហេតុនេះសូមលោកគ្រូពន្យល់បញ្ជាក់ថែមទៀតដើម្បីដាស់សតិក ។

## វិធីហាត់មាត់ទទេ

ដើមកប្បាសកំពស់ប៉ុន្មានម៉ែត្រ ? ផ្កាវាដូចម្តេច ? ផ្លែវាគេហៅថាអ្វី ? គេដាំយ៉ាងដូចម្តេច ? គេដាំនៅខែណា ? គេច្រើនដាំកប្បាសនៅខែត្រណា ? កប្បាសទុំនៅខែណា ? បើមានកៀនផ្លែកប្បាសល្អឬទេ ? គេយកសំឡីកប្បាសទៅធ្វើអ្វី ? គ្រាប់វាគេយកទៅធ្វើអ្វី ?

## តែងសេចក្ដីទី ១

ចូរតែងសេចក្ដីអធិប្បាយអំពីការដាំកប្បាសដែលអ្នកបានឃើញ ឬក៏ឮដោយគ្រូនិយាយប្រាប់

## របៀបអធិប្បាយ

១– អំពីដើមផ្កានិងផ្លែកប្បាស ។ ២– អំពីរដូវនិងរបៀបដាំ ។
៣– អំពីរដូវបេះ ។ ៤– អំពីប្រយោជន៍នៃកប្បាស ។
៥– អំពីយោបល់យល់ឃើញរបស់អ្នក ។

## គំរូតែងសេចក្ដី

១ កប្បាសជារុក្ខជាតិតូចកំពស់មួយម៉ែត្រឬមួយម៉ែត្រកន្លះ ផ្កាវាពណ៌លឿងឆ្អុស ផ្លែវាបែបជាឡូតមានសំឡីទន់រុំព័ទ្ធជុំវិញគ្រាប់ខ្មៅ ។ ២ គេដាំកប្បាសនៅខែមករា កុម្ភៈ ដោយដាក់គ្រាប់ក្នុងរណ្ដៅតូច ៗ ។ ៣ គេបេះផ្លែកប្បាសនៅរដូវប្រាំង ។ ៤ កប្បាសមានប្រយោជន៍ណាស់ គេយកសំឡីទៅធ្វើអំបោះត្បាញសំពត់ ។ ៥ យោបល់ខ្ញុំយល់ឃើញថា បើគ្មានអំបោះកប្បាស យើងមិនងាយរកអំបោះធ្វើសំពត់អាវស្លៀកពាក់ទេ ហេតុនេះត្រូវតែដាំកប្បាសឲ្យច្រើន ។

## តែងសេចក្ដីទី ២

ចូរតែងសេចក្ដីអធិប្បាយអំពីការត្បាញសំពត់នៅក្នុងស្រុកអ្នក ។

## របៀបអធិប្បាយ

១– សេចក្តីផ្តើម ។ ២– អំពីកុទធីនិងរបៀបត្បាញ ។ ៣– អំពីសំពត់ត្បាញនិងប្រយោជន៍ផ្សេងៗ ។ ៤ សេចក្តីបញ្ចប់ ។

## តែងសេចក្តីទី ៣

ចូរតែងសេចក្តីអធិប្បាយអំពីការជ្រលក់សំពត់ដែលអ្នកធ្លាប់បានឃើញម្តាយអ្នកឬមនុស្សជិតខាងអ្នកធ្វើ ។

## របៀបអធិប្បាយ

១– សេចក្តីផ្តើម ។ ២= អំពីប្រើពណ៌ផ្សេងៗ ។ ៣– អំពីរបៀបជ្រលក់សំពត់ ។ ៤– អំពីពណ៌ដែលអ្នកស្រឡាញ់ជាងពណ៌ឯទៀត ហេតុអ្វី?

សូមមើលរបៀបពន្យល់ខាងលើ

---

បរិច្ឆណាដ្ឋាន

## តែងសេចក្តី

## វិធីហាត់មាត់ទទេ

អំពីរុក្ខជាតិដែលគេនាំយកសំឡីមកធ្វើសំលៀកបំពាក់ ។

អ្នកស្គាល់រុក្ខជាតិអ្វីខ្លះ ដែលគេនាំយកសំឡីមកធ្វើជាសំលៀកបំពាក់ (កប្បាស-គរ) ។ គេយកសំឡីកប្បាសគរទៅធ្វើដូចម្តេចឲ្យកើតជាអំបោះ? (រវៃ) ។ គេរវៃអំបោះនឹងអ្វី? (កុង)

គេយកអំបោះទៅធ្វើដូចម្ដេចឲ្យកើតទៅជាសំពត់? (ត្បាញ)

គេត្បាញសំពត់នឹងអ្វី ? (កី)

## តែងសេចក្ដីទី ១

ចូរតែងសេចក្ដីអធិប្បាយអំពីសំពត់តាមពាក្យចោទខាងក្រោមនេះ ៗ អ្នកស្គាល់សំពត់អ្វីខ្លះ ? សំពត់ហូលផាមួង ព្រោគេធ្វើនឹងសរសៃអ្វី ? សំពត់ផាឌិបទេសឯកគេធ្វើនឹងសរសៃអ្វី ? សាខ្វាតធ្វើនឹងអ្វី?

រដូវក្ដៅអ្នកចូលចិត្តសំលៀកបំពាក់ដូចម្ដេច ? រដូវត្រជាក់អ្នកចូលចិត្តសំលៀកបំពាក់ដូចម្ដេច ?

## គំរូតែងសេចក្ដី

សំពត់ដែលខ្ញុំស្គាល់នោះគឺ ផាឌិប ទេសឯក ផាមួង ល្បើក, ហូល, សាខ្វាត, សំពត់ហូលផាមួងគេធ្វើនឹងសរសៃសូត្រ ៗ សំពត់ផាឌិប ទេសឯក គេធ្វើនឹងសរសៃអំបោះ ៗ សាខ្វាតធ្វើនឹងរោមចៀម ៗ រដូវក្ដៅខ្ញុំចូលចិត្តស្លៀកពាក់សំពត់អាវស្ដើង ៗ រដូវត្រជាក់ខ្ញុំចូលចិត្តស្លៀកពាក់ខោអាវក្រាស់ ៗ

## តែងសេចក្ដីទី ២

ចូរអធិប្បាយអំពីការដំបាញ ដែលអ្នកបានឃើញនៅក្នុងភូមិអ្នក តាមពាក្យចោទខាងក្រោមនេះ ៗ

អ្នកដែលឃើញគេត្បាញសំពត់ឬទេ ? គេត្បាញនឹងអ្វី ? មុននឹងត្បាញគេធ្វើដូចម្ដេចខ្លះ ? អ្នកចូលចិត្តនឹងការដំបាញឬទេ ? ពីព្រោះអ្វី ?

## សេចក្ដីតែងទី ៣

ចូរអធិប្បាយអំពីគ្រឿងប្រដាប់ជាងកាត់ខោអាវ នឹងរបស់ដែលមាននៅក្នុងផ្ទះវាតាមពាក្យចោទខាងក្រោមនេះ ៗ

អ្នកដែលទៅជួលចិនកាត់ខោអាវឬទេ ? ចិនវាវាស់ខ្លួនអ្នកនឹងអ្វី ? នៅក្នុងផ្ទះវាអ្នកបានឃើញរបស់អ្វីខ្លះ ? វាដាក់នៅឯណា ? អ្នកចូលចិត្តនឹងជាងកាត់ខោអាវឬទេ ? ពីព្រោះអ្វី ?

---

## អាធិកដ្ឋាន

**គណិត**

អាទិត្យទី ១.– លេខគុណចំនួនដុំ

(មេគុណមានលេខពីរខ្ទង់) សូមមើលសៀវភៅនព្វន្ត ទំព័រ ៩២

វិធីហាត់មាត់ទទេ.– សំពត់ទេសឯកមួយម៉ែត្រថ្លៃ ១៨៛ តើសំពត់ទេសឯក ៤០ ម៉ែត្រថ្លៃប៉ុន្មាន ? ចានមួយឡូថ្លៃ ២៣០៛ តើចាន ៣០ ឡូថ្លៃប៉ុន្មាន ?

(សូមរកដាក់ឲ្យសិស្សធ្វើឲ្យបានច្រើនផងចុះ)

វិធីហាត់សរសេរ.- បំណោទ.- ឈ្មួញម្នាក់បានទិញមួកចាស់ ៣០ ឡូថ្លៃ ១២៨ រៀលមួយឡូ អ្នកនោះលក់រាយទៅវិញ ថ្លៃ ១២ រៀលមួកមួយ ។ តើឈ្មួញនោះចំណេញបានប៉ុន្មាន ?

លេខចែកចំនួនធំ (លេខហារមានលេខពីរខ្ទង់) សូមមើលសៀវ-ភៅដដែលទំព័រ ៩៩ ។

វិធីហាត់មាត់ទទេ.- មាន់ ៣ ថ្លៃ ៣៦ រៀល តើមាន់មួយថ្លៃប៉ុន្មាន ? សំពត់ព្រែ ២២ ម៉ែត្រថ្លៃ ៦៦០ រៀល តើសំពត់មួយម៉ែត្រថ្លៃប៉ុន្មាន ?

វិធីហាត់សរសេរ.- បំណោទ- សំពត់ ៩ ម៉ែត្រថ្លៃ ២៣៤ រៀល តើប្រាក់ចំនួន ១៨២ រៀលទិញបានសំពត់ប៉ុន្មានម៉ែត្រ ។

អាទិត្យទី ២.- លេខគុណនឹង ១០-១០០-១០០០- សៀវភៅសរសេរមួយថ្លៃ ៥ រៀល បើសៀវភៅ ១០ ថ្លៃប៉ុន្មាន ? ។ យើងដឹងថាសៀវភៅមួយថ្លៃ ៥ រៀល បើសៀវភៅដប់ថ្លៃ ៥ រៀល ១០ ដងគឺថា ៥ ដប់ដងត្រូវជា ៥០ ។ ប៉ុន្តែបើយើងគុណចំនួនប៉ុន្មានៗក្តីនឹង ១០-១០០-១០០០ នេះ គេមិនចាំបាច់ធ្វើលេខគុណដូចធម្មតាទេ គ្រាន់តែថែមសូន្យមួយនៅខាងស្តាំចំនួននោះ បើគុណនឹង ១០០ ។ សូន្យបី បើគុណនឹង ១០០០ ។

អៀនឡើបាំមាត់ ៖ បើកាលណាត្រូវគុណចំនួនអ្វីមួយៗនឹង ១០-នឹង ១០០ នឹង ១០០០ នោះគេមិនចាំបាច់ធ្វើលេខទេ គេគ្រាន់តែថែមសូន្យមួយ (០) បើគុណនឹង១០ ។ សូន្យ (០០) បើគុណនឹង ១០០ ។ សូន្យ (០០០) បើគុណនឹង ១០០០ ។ល។

ឧបមាដូចជា ៨១ គុណនឹង ១០ ។ ត្រូវជា ៨១០ ។ គុណនឹងមួយរយត្រូវជា ៨១០០ ។ គុណនឹង ១០០០ ត្រូវជា ៨១០០០ ។

វិធីហាត់គិតក្នុងខួរ ៖— ចូរធ្វើលេខខាងក្រោមនេះ ។

៦៧ × ១០ ។ ៤៣៤ × ១០០០ ។ ៩៣៨ × ១០០០ ។ ១០៤៦ × ១០០០ ។ ៧៦៣ × ១០០ ។ ២៣៧ × ១០០ ។

បំណោទ — សម្មាញខ្ញុំម្នាក់ទិញសៀវភៅសរសេរ ១០ ថ្ងៃមួយ ៥ រៀល ទឹកខ្មៅ ៣ ដបថ្ងៃមួយដប ១០ រៀល

គេសួរថាសំឡាញ់ខ្ញុំចាយអស់ប្រាក់ប៉ុន្មាន?

អាទិត្យទី ៣ — លេខចែកនឹង ១០-១០០-១០០០ ។ បាន ១០ ថ្ងៃ ៦០ រៀល តើបានមួយថ្ងៃប៉ុន្មាន? យើងដឹងថាបាន ១០ ថ្ងៃ ៦០ រៀល បើបានមួយថ្ងៃត្រូវចែកជាដីគឺៈ ៦០ ៖ ១០ = ៦ រៀល ។ ប៉ុន្តែនឹងចែកលេខចំនួនប៉ុន្មានៗក្តី នឹង ១០-១០០-១០០០ នេះគេមិនចាំបាច់ដូចជម្មតាទេ គេគ្រាន់តែបន្ថយកណ្តក់សញ្ញាពីខាងស្តាំទៅខាងឆ្វេង

មួយខ្ទង់សំរាប់ចែកនឹង ១០ ។ ពីរខ្ទង់សំរាប់ចែកនឹង ១០០ ។ បីខ្ទង់សំរាប់ចែកនឹង ១០០០ ។ល។ ឧបមាដូចជាប្រាក់ ៨៩២០៛, ចែកនឹង១០ ត្រូវបាន ៨៩២០ ។ ៨៩២០ ចែកនឹង ១០០ ត្រូវបាន ៨៩៛២០ ។ ៨.៩២០ ចែកនឹង ១.០០០ ត្រូវ ៨៛៩២ ។ល។

មេរៀនឡើបាំមាត់– បើកាលណាត្រូវចែកចំនួនមួយៗនឹង ១០-១០០-១០០០ នោះគេមិនបាច់ធ្វើលេខទេ គេត្រូវតែបន្ថយកណ្ដក់សញ្ញាពីស្ដាំទៅឆ្វេង មួយខ្ទង់បើចែកនឹង ១ ពីរខ្ទង់បើចែកនឹង ១០០ បីខ្ទង់បើចែកនឹង ១.០០០ ។ល។

## វង្វាស់វង្វាល់

### អាទិត្យទី ១– គីឡូម៉ែត្រ

ពីភូមិយើងទៅភូមិ ...... នោះមានចម្ងាយប៉ុន្មាន ។ ពីភូមិយើងទៅសាលាខេត្តមានចម្ងាយប៉ុន្មាន ? គីឡូម៉ែត្រគេសំរាប់ទុកធ្វើអ្វី ? គេសំរាប់ទុកសំគាល់ប្រវែងផ្លូវថ្នល់ សំគាល់ចម្ងាយពីស្រុកមួយទៅស្រុកមួយឬសំគាល់ជុំវិញព្រះនគរ ។

ហេតុយ៉ាងនេះគីឡូម៉ែត្រជាខ្នាតវង្វាស់ប្រវែង ។

ពាក្យនេះកើតមកពីពាក្យពីរម៉ាត់ " គីឡូ " នឹងម៉ែត្រ ។ ឯចំណែកម៉ែត្រនោះយើងបានរៀនហើយ គីឡូគឺមួយពាន់ម៉ែត្រ ។ គឺជាខ្នាតរង្វាស់មានប្រវែង ១.០០០ ម៉ែត្រគេសរសេរកាត់ គ.ម.

វិធីហាត់សរសេរ – ប្តូរចំនួនលេខខាងក្រោមធ្វើឲ្យជាម៉ែត្រវិញ ។

៣ ហ.ម + ៥ ដា.ម + ៤៥ ដា.ម = ។ ៨ ហ.ម + ៤ ហ.ម + ៧ ដា.ម ៨ ម + ៣៨ = ។ ៨ ហ.ម ៧ ម - ៤ ហ.ម - ៥ ម ។ ៧ ហ.ម. ៦.ម. + ៤០ ដា.ម ។ ៩ ហ.ម - ១០ ម = ។

ចំណោទ.– ១– ពីព្រៃនគរមកភ្នំពេញមានចម្ងាយ ២៤១ គីឡូម៉ែត្រ ពីភ្នំពេញទៅបាត់ដំបងមានចំងាយ ២៩៣ គីឡូម៉ែត្រ ។ មានប្រវែងប៉ុន្មានគីឡូម៉ែត្រពីព្រៃនគរទៅបាត់ដំបង ។

២– មានរថយន្តមួយបើកក្នុងមួយម៉ោងបាន ៦០ គីឡូម៉ែត្រ គេសួរថារថយន្តនោះបើកបានប៉ុន្មានម៉ែត្រក្នុងមួយមិនុត ? ។

អាទិត្យទី ២.- អំពីគីឡូក្រាម

សូមយកជញ្ជីងនិងកូនទម្ងន់គ្រប់បែប ធ្វើពីដែកនិងស្ពាន់ដែលមានទម្ងន់មួយគីឡូក្រាមដូចគ្នាមកបង្ហាញសិស្ស ហើយសូមបង្រៀនសិស្សឲ្យថ្លឹងសៀវភៅ ប្រអប់ដីស ដុំថ្ម ដុំឥដ្ឋ ។ល។ រួចហើយ

សូមបង្រៀនឲ្យស្មានទម្ងន់វត្ថុផ្សេង ៗ កាលណាស្មានហើយត្រូវឲ្យថ្លឹងផ្ទៀងមើលនៅមុខសិស្ស បើឃើញចំនួនត្រឹមត្រូវហើយឲ្យសិស្សថាជាក្រាម. ដេកាក្រាម . ហិកតូក្រាម . គីឡូក្រាម មួយគីឡូក្រាមនេះគឺមានទម្ងន់ ១០ ហិកតូក្រាម ១០០ ដេកាក្រាម ១០០០ ក្រាមគីឡូក្រាមនេះគេសរសេរកាត់ ( គក្រ )

**វិធីហាត់គិតមាត់ទទេ** – ចូររៀបចំទំនិញផ្សេង ៗ ដែលគេត្រូវថ្លឹងលក់នោះ ទីងថ្លឹងវត្ថុផ្សេង ៗ គេថ្លឹងនឹងអ្វី ? កូនទម្ងន់គេធ្វើនឹងអ្វី? មួយគីឡូក្រាមមានប៉ុន្មាន ហិកតូក្រាម ? ប៉ុន្មានដេកាក្រាម ? ប៉ុន្មានក្រាម គីឡូក្រាមគេសរសេរកាត់យ៉ាងដូចម្តេច ? ។ល។

**វិធីហាត់គិតក្តារខ្មៀន** – ទឹកសុទ្ធមួយលីត្រមានទម្ងន់មួយគីឡូក្រាម បើទឹកសុទ្ធ ៤ លីត្រមានទម្ងន់ប៉ុន្មាន ? ត្រូវមានទឹកសុទ្ធប៉ុន្មានលីត្របើគេចង់ឲ្យបានទម្ងន់ ១៥ គីឡូក្រាម ២ គីឡូក្រាមត្រូវជាប៉ុន្មានក្រាម ? ប៉ុន្មានដេកាក្រាម - ប៉ុន្មានហិកតូក្រាម ត្រូវប៉ុន្មានហិកតូក្រាម ទើបធ្វើឲ្យបាន២ គីឡូក្រាម? ៣ គីឡូក្រាម? ៥ គីឡូក្រាម? ៨គីឡូក្រាម ? ។ល។

អាធិត្យទី ៣.– អំពីកង់តាល់នឹងតោន

កាលណាគេនិយាយអំពីទម្ងន់បំណុះរទេះ រថយន្តបំណុះទូក ឬកប៉ាល់ គេមិននិយាយថារទេះនេះដឹកស្រូវ ១.២០០ គីឡូក្រាម ។ រថយន្តនេះដឹកបាន ៥.០០០ គ.ក្រ. ទេ ។ គេត្រូវនិយាយថារទេះនេះមានបំណុះ

១២ កាំង៏តូ ។ រថយន្តនេះមានចំណុះ ៥០ កាំង៏តូ ឬ ៥ តោន ។ មួយកាំង៏តាល់មានទម្ងន់ ១០០គីឡូក្រាម មួយតោនមាន ១.០០០គីឡូក្រាម ។ ឧបមាដូចជា ៥០០ គ.ក្រ ត្រូវជា ៥ កាំង៏តូ ២៨-០០០ គ.ក្រ ត្រូវជា ២៨ តោន ៧ កាំង៏តូត្រូវជា ៧ គ.ក្រ. ។

៣៥ កាំង៏តូត្រូវជា ៣.៥០០ គ.ក្រ. ត្រូវជា៦តោន ។ ៤៧-០០០- គ.ក្រ. ត្រូវជា ៤៧ តោន ។ គេសរសេរកាត់ "ក" សំរាប់កាំង៏តាល់ "ត" សំរាប់តោន

វិធីហាត់គិតក្ដារផ្ទួន គ្នី ៦.៤០០ គ.ក្រ. មានប៉ុន្មានតោន ប៉ុន្មានកាំង៏តូ ?

១៣៧.០០០ គ.ក្រ- មានប៉ុន្មានតោនប៉ុប៉ុន្មានកាំង៏តូ ? ៥៦៩៨- កាំង៏តូមានប៉ុន្មានគីឡូក្រាម ? ។ល។

បំណោទ :— គ្នីគេឱ្យម៉ាស៊ីនកិនស្រូវមួយមានស្រូវ ៨០០តោន មួយថ្ងៃ ។ កិនបានស្រូវ ៩០ កាំង៏តូ ដល់ទៅប៉ុន្មានថ្ងៃទៅសល់ស្រូវប៉ុន្មាន តោនទឹងកិនទៀត ។

អាទិត្យទី៤- អំពីថាំង-តៅ កន្ទាំង

សូមមើលសៀវភៅក្បួនទន្ទឹងកិច្ចការទំព័រ ១១៥ ។

ខ្មែរប្រើថាំងសម្រាប់វាល់ស្រូវនិងគ្រាប់ធាន់ៗដូចយ៉ាងពោត-សណ្ដែក ។

# អំពីផ្ទៃត្រីកោណ

ឧបមា: ថ្នាលមួយរាងត្រីកោណបាតប្រវែង ៦ ម៉ែត្រកំពស់ ៣ ម៉ែត្រ តើថ្នាលនោះមានប៉ុន្មានម៉ែត្រក្រឡា ?

វិធីរកផ្ទៃត្រីកោណ គេគុណបាតនឹងកំពស់ រួចឃើញលទ្ធប៉ុន្មានគេយកពាក់កណ្ដាល ។

គឺ ១ម២. $\frac{៦ \times ៣}{២}$ = ៩ ម២




វិធីហាត់មាត់ទទេ ក្រដាសមួយផ្ទាំងរាងត្រីកោណបាត ២៥ ស.ម កំពស់ ១៦ ស.ម តើផ្ទៃក្រដាសមានប៉ុន្មានសង់ទីម៉ែត្រក្រឡា ? (សូមរកដាក់ថែមទៀតឲ្យបានច្រើនផងចុះ)

## ហាត់សរសេរ.- បំណោទ

បំការមួយរាងត្រីកោណបាត ២៥៤ ម កំពស់ ១៨៤ ម តើបំការនោះមានទំហំប៉ុន្មានម៉ែត្រក្រឡា? ។

# មជ្ឈមដ្ឋាន ទី ១

## គណិត

### អាទិត្យទី ១.– ចំនួនបែងភាគគត់

ការដែលមានប្រយោជន៍បំផុតនោះ ត្រូវឲ្យសិស្សធ្វើកិច្ចជាមួយផងឲ្យបានជាក់ស្តែងនឹងភ្នែក ៗ ហេតុនេះក្នុងសិស្សម្នាក់ៗត្រូវឲ្យមានក្រដាសពីរសន្លឹក ដើម្បីនឹងផ្តើមហេតុរៀនវិធីហាត់បែងភាគគត់នេះឲ្យបានច្រើនគួរសម ទើបនាំឲ្យសិស្សបានដឹងជាក់ច្បាស់ក្នុងកិច្ចនេះ ៗ យើងយកក្រដាស១សន្លឹក យើងបត់ហើយកាត់តាមផ្នត់នោះជា ៨ ចំណែកឲ្យស្មើគ្នាមួយចំណែក ៗ ហៅថាភាគ ៨ ពីក្រដាសមួយសន្លឹកគត់ ចូរកាត់តាមផ្នត់ឲ្យខុសបែប ខុសចំនួនចំណែកពីមុនតែឲ្យស្មើគ្នាជានិច្ចរួចយកចំណែកមួយឬចំណែកទាំងនោះមកហៅ ហើយប្រាប់ឈ្មោះតាមដែលបែងភាគ ៗ

វិធីហាត់មាត់ទទេ.– សូមជ្រើសក្នុងក្បួនគណិតអាទិកដ្ឋាន ទំព័រ ៧៤-៧៩ ៗ

វិធីហាត់សរសេរ.– សូមមើលទំព័រដដែលដាក់ឲ្យសិស្សធ្វើ ៗ

អាទិត្យទី២.– វិធីបូកចំនួនបែងភាគគត់

(សូមមើលរបៀបបង្រៀនក្នុងក្បួននព្វន្តអាទិកដ្ឋាន ទំព័រ ៨៥)

អាទិត្យទី ៣.- លេខចែកចំនួនជុ

( ផលហារមានតែមួយខ្ទង់ )

១– ចំនួនខ្ទង់ទី ១ ធំជាងផលហារ : ៧៤ : ៣ = ៦

២– ចំនួនតាំងខ្ទង់ទី ១ តូចជាងផលហារ : ៤២ : ៧ = ៦

( សូមមើលសៀវភៅដដែលទំព័រ ៩៧ )

## រង្វាស់រង្វាល់

អំពីកាំងតាល់និងតោន

( សូមមើលរបៀបនៅអាទិកដ្ឋានខាងលើនេះ )

សូមបង្ហាត់ចំណុះនេះឲ្យត្រឹមត្រូវ សូវបំបែកឲ្យបានច្រើនផង ៗ

## ធរណីមានសាស្ត្រ

មជ្ឈិមដ្ឋានទី ១ និងអាទិកដ្ឋាន

សេចក្ដីរំឭក_ សូមគ្រូពន្យល់សិស្សឲ្យយល់ច្បាស់អំពីម៉ែត្រលាតនិងម៉ែត្រក្រឡានោះខុសគ្នាបែបណា ១– ម៉ែត្រក្រឡាគឺជាផ្ទៃមួយ

បួនជ្រុងស្មើដែលក្នុង ១ ជ្រុងមានប្រវែង ១ វែងម៉ែត្រកាយ ៗ ម្យ៉ាងទៀតក្នុង រង្វាស់ផ្ទៃខ្នាតទាំងឡាយតូចធំជាងគ្នា ១០០ ដង ពុំដូចនៅក្នុងរង្វាស់ ប្រវែងឡើយ ដែលខ្នាតទាំងតូចធំជាងគ្នា ១០ ដង ៗ ១ ម៉ែត្រក្រឡា សរសេរកាត់ជា ( ១ម២ )

## អាទិត្យទី ១ ទី ២.- ផ្ទៃបួនជ្រុងស្មើ

របៀបបង្រៀន.- គូរបួនជ្រុងស្មើនៅក្ដារខៀនជ្រុងមួយ ៗ ប្រវែង៥ ដ.ម ដោយចុចគ្រប់តែកំណាត់ ១ ដ.ម. ហើយគូសភ្ជាប់ពីចំណុចជ្រុងមួយ ទៅចំណុចជ្រុងមួយទៀតកើតជាក្រឡាចតុរង្គ ៖ បួនជ្រុងស្មើធំត្រូវចែកជា បន្ទះ ៥ ជួរក្នុងមួយជួរមានបួនជ្រុងស្មើទំហំ ១ ដ.ម. ក្រឡា ៥ ដែរ ។ ដូច្នេះក្រឡាផ្ទៃបួនជ្រុងស្មើកើតឡើងដោយ ៥ដម × ៥ដម = ២៥ដ.ម២ ។

វិធាន ដើម្បីរកក្រឡាផ្ទៃនៃបួនជ្រុងស្មើ គេត្រូវយកប្រវែងជ្រុង គុណនឹងប្រវែងជ្រុងដូចគ្នា ។

ឧបមា : ស្រែបួនជ្រុងស្មើ ១ មានប្រវែង ២៥ម ក្នុង ១ ជ្រុងផ្ទៃស្រែនោះ គឺ១ ម២ × ២៥×២៥ = ៦២៥ ម២ ។

## អាទិត្យទី ៣ នឹង ទី ៤.- ផ្ទៃនៃបួនជ្រុងទ្រវែង

វិធាន ដើម្បីរកក្រឡាផ្ទៃនៃបួនជ្រុងទ្រវែងគេត្រូវយកប្រវែងទទឹង គុណនឹងប្រវែងបណ្ដោយ ។

របៀបបង្រៀន– មិនខុសគ្នាពីរបៀបបង្រៀនបួនជ្រុងស្មើប៉ុន្មានទេ គ្រាន់តែមួយជ្រុងទ្រវែងមានបណ្ដាយប៉ុណ្ណោះ

កំណត់សំគាល់ – ត្រូវវាស់ប្រវែងទទឹងនឹងបណ្ដាយបួនជ្រុងទ្រវែងដោយខ្នាតតែមួយ ៗ

សុំបង្រៀនសិស្សឲ្យចេះបំបែកខួរឲ្យបានស្ទាត់មែនទែន នឹងរកបំណោទផ្សេង ៗ ឲ្យក្មេងធ្វើឲ្យបានច្រើន ៗ

---

បរិវច្ឆណដ្ឋាន



មេរៀនទី ១.– អំពីចំនួនបែងភាគគត់

ក្នុងការបង្រៀនរង្វាស់-រង្វាល់ សិស្សបានស្គាល់រង្វាស់ដែលតូចជាងម៉ែត្រ រង្វាល់ដែលតូចជាងលីត្រ ទម្ងន់តូចជាងក្រាម ៗ វិជ្ជាទាំងនោះនាំឲ្យយើងបង្រៀនចំនួនទសភាគ ឯការបង្រៀនចំនួនទសភាគនេះត្រូវឲ្យសិស្សស្គាល់ចំនួនដុំកណ្ដាក់សញ្ញា - ចំនួនភាគដប់ - ភាគរយភាគពាន់ ៗ

របៀបបង្រៀន.–

១– គ្រូថាចំនួនទសភាគមួយដូចជា ៥៛៧៣ ៗ ២ម៉ ៤៥ ៣លិ២៦ ៗ

២ – គ្រូសរសេរចំនួនទាំងនោះនៅលើក្ដារខៀនហើយពន្យល់សិស្សឲ្យស្គាល់ចំនួនដុំ - កំណត់សញ្ញា . ចំនួនភាគជប់ . ភាគរយ ៗ

៣ – គ្រូអានចំនួននោះហើយឲ្យសិស្សអានតាមរួចសួរបញ្ជាក់អំពីរបៀបអាននោះ

៤ – គ្រូថាចំនួនទសភាគមួយឲ្យសិស្សសរសេរនៅលើក្ដារខៀនហើយសួរសាកអំពីរបៀបសរសេរនោះ

៥–ការហាត់អានចំនួនទសភាគ - គ្រូចង្អុលចំនួនទសភាគដែលមានសរសេរនៅលើក្ដារខៀនឲ្យសិស្សអាន

៦ - ការហាត់សរសេរចំនួនទសភាគ-គ្រូថាចំនួនទសភាគ ឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន

៧– ការហាត់សរសេរនៅក្នុងសៀវភៅ - សូមតែងការហាត់នេះដាក់ឲ្យសិស្សធ្វើផង ៗ

មេរៀនទី២.= ចំនួនទសភាគ . លេខបូកនិងលេខសង

មេរៀនទី៣.– ចំនួនទសភាគ-គុណចំនួននឹង ៩

មេរៀនទី៤.- ចំនួនទសភាគ - ចែកលេខនឹង ៩

សូមធ្វើតាមរបៀបដែលបានធ្វើមុន ៗ មកហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ៗ

# រង្វាស់រង្វាល់

កន្លែងនេះត្រូវបង្រៀនអំពីរង្វាស់ រង្វាល់ . កូនទម្ងន់ ដែលមានជាប្រាកដសម្រាប់ប្រើប្រាស ។

មេរៀនទី ១– អំពីរង្វាស់ដែលមានប្រាកដ ៖

ដេកាម៉ែត្រក្លោះ ដេកាម៉ែត្រ កន្លះដេកាម៉ែត្រ

ម៉ែត្រក្លោះ ម៉ែត្រ កន្លះម៉ែត្រ

ដេស៊ីម៉ែត្រក្លោះ ដេស៊ីម៉ែត្រ

ការចំណាំ – រង្វាស់គីឡូម៉ែត្រ - ហិកតូម៉ែត្រ - សង់ទីម៉ែត្រ - មីលីម៉ែត្រ មានតែឈ្មោះសម្រាប់ហៅសំរាប់គិតក្នុងចិត្ត បើត្រូវការវាស់ គេប្រើរង្វាស់ ដេកាម៉ែត្រ - ម៉ែត្រ - ដេស៊ីម៉ែត្រ ។

មេរៀនទី ២– អំពីរង្វាស់ដែលមានជាប្រាកដ

| | | |
|---|---|---|
| | ហិកតូលីត្រ | កន្លះហិកតូលីត្រ |
| ដេកាលីត្រក្លោះ | ដេកាលីត្រ | កន្លះដេកាលីត្រ |
| លីត្រក្លោះ | លីត្រ | កន្លះលីត្រ |
| ដេស៊ីលីត្រក្លោះ | ដេស៊ីលីត្រ | កន្លះដេស៊ីលីត្រ |
| សង់ទីលីត្រក្លោះ | សង់ទីលីត្រ | |

ការចំណាំ– តាំងពីរង្វាស់ហិកតូលីត្ររហូតដល់សង់ទីលីត្រ គេសង្កេតឃើញគ្នោះហើយទឹងកន្ទុះ ។

## មេរៀនទី ៣.– អំពីកូនទម្ងន់ដែលមានជាប្រាកដ

ក - កូនទម្ងន់ធ្វើអំពីសំណប៉ាហាំង ៖

៥០ គក្រ - ២០ គក្រ - ១០ គក្រ - ៥ គក្រ - ២ គក្រ - ១គក្រ
៥ ហក្រ - ២ ហក្រ - ១ ហក្រ - ៥ ដាក្រ ។

ខ- កូនទម្ងន់ធ្វើអំពីស្ពាន់ ៖

៥គក្រ - ២គក្រ - ១គក្រ - ៥ហក្រ - ២ហក្រ - ១ហក្រ -
៥ដាក្រ - ២ដាក្រ - ១ដាក្រ - ៥ក្រ - ២ក្រ - ១ក្រ -

គ - កូនទម្ងន់ធ្វើអំពីបន្ទះ ស្ពាន់ឬនិកិល ៖

៥ ដក្រ - ២ ដក្រ - ១ ដក្រ
៥ សក្រ - ២ សក្រ - ១ សក្រ
៥ មក្រ - ២ មក្រ - ១ មក្រ ។

ការចំណាំ– តាំងពីកូនទម្ងន់ ៥០ គ.ក្រ រហូតដល់កូនទម្ងន់១ មក្រ គេសង្កេតឃើញគ្នោះនឹងកន្ទុះ ។

## មេរៀនទី ៤ – សាបស្រៀនពីដើមឡើង

សូមតែងការហាត់ឲ្យសព្វគ្រប់តាមរបៀបដែលមានពីខែមុន ៗ មក ។

## កុមារដ្ឋាន

### នព្វន្ត

មេរៀនទី ១.– ចំនួនពី ៧០ ដល់ ៧៩

ការរៀនរាប់ - រៀនគាន - រៀនសរសេរចំនួន

របស់សំរាប់បង្រៀន – ចង្កឹះបាច់ ៧ បាច់ និងចង្កឹះរាយ ១០ ឬប្រាក់កាក់ ១០ សេន ៧ និងលុយសេន ១០

របៀបបង្រៀន.–

១ – មតិសំខ្យា – ឲ្យសិស្សរាប់ចង្កឹះឬលុយបន្ថែម ២ - ៣ - ៤ ពី ១ ដល់ ៦៩ ហើយរាប់បន្ថយមកវិញ ។

២ – ការរៀនរាប់ចំនួន – គ្រូលើកចង្កឹះឬលុយ ៦៩ បង្ហាញសិស្ស ហើយបន្ថែម ១ ទៅទៀត ។ សួរសិស្សថា ត្រូវជាប៉ុន្មាន ។ មាន ១០ ប៉ុន្មានដង ។ គ្រូសរសេរចំនួន ៧០ នៅលើក្ដារខៀនហើយពន្យល់របៀបសរសេរចំនួននោះ ។

៣ - ការរៀនគានចំនួន គ្រូឲ្យសិស្សគានចំនួននោះឲ្យបានច្រើនគ្នា

៤– ការរៀនសរសេរចំនួន– ឲ្យសិស្សសរសេរចំនួន ៧០ នៅលើក្ដារខៀន បាន ៤ ឬ ៥ នាក់ រួចឲ្យសរសេរនៅលើក្ដារឆ្នួនទាំងអស់គ្នាធ្វើតាមរបៀបនេះរហូតដល់ ៧៩ ។

## ការហាត់បញ្ជាក់ឡើងវិញ

ក - រាប់ចំនួន – គ្រូលើកបង្កើះឬលុយឲ្យសិស្សថាចំនួន ឬគ្រូថាចំនួនឲ្យសិស្សលើករបស់បង្ហាញ

ខ - អានចំនួន = គ្រូបង្អុលចំនួនសរសេរនៅលើក្ដារខៀនឲ្យសិស្សអាន ឬថាចំនួនឲ្យសិស្សបង្អុល ៗ

គ- សរសេរចំនួន– គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន ៗ

ការហាត់សរសេរនៅក្នុងសៀវភៅ .- បើសិស្សចេះសរសេរក្នុងសៀវភៅហើយសូមតែងការហាត់ដាក់ឲ្យសិស្សធ្វើផង ៗ

មេរៀនទី២ .- ចំនួនដល់៧៩

រៀនធ្វើលេខបូកមានត្រាទុក ៗ

## របៀបបង្រៀន

១ - មតិសំខាន់ – ឲ្យសិស្សរាប់បន្ថែមពីរ ៗ បី ៗ បួន ៗ ពីមួយដល់ ៧៩ រួចរាប់បន្ថយមកវិញ

២ - ពន្យល់របៀបធ្វើលេខបូកមានត្រាទុក .-

```
+ ២៧ស
  ៣៤ស
 -----
  ៦១ស
```

គ្រូនាំសិស្សទាំងអស់គ្នាធ្វើលេខបូកនេះ (៧+៤= ១១ គេត្រូវសរសេរចំនួន ១ នៅខ្ទង់រាយ នៅក្រោមខ្ទង់រាយ ហើយគេត្រាទុក ១ នៅខ្ទង់ ១០ ដើម្បីនឹងបញ្ចូលជាមួយខ្ទង់ ១០៖ ១+២+៣ = ៦)

៣ – ការហាត់បញ្ជាក់នៅលើក្ដារខៀន. - ឲ្យសិស្សធ្វើលេខបូក ខាងក្រោមនេះនៅលើក្ដារខៀន ៣៥ស+១៨ស = ។

២៩ស+១៦ស = ។ ២៥ស+៣៨ស = ។

៤ – ការហាត់បញ្ជាក់នៅលើក្ដារជួន ។

៥ – កាហាត់សរសេរនៅក្នុងសៀវភៅ ។

សុំលោកគ្រូតែងការហាត់ទាំងនោះផង

មេរៀនទី ៣.– ចំនួដល់ ៧៩

លេខសងមានត្រាទុក

មេរៀនទី ៤.– ចំនួនដល់ ៧៩

មេលេខគុណនឹង២

មេរៀនទី៥.– ចំនួនដល់ ៧៩

រៀនគុណចំនួននឹង២ ( ទ្វេគុណ )

មេរៀនទី ៦.– ចំនួនដល់ ៧៩

រៀនបែកចំនួនជាពីរ ( ពាក់កណ្ដាល )

សុំមើលតាមរបៀបរៀបចំខាងលើ ហើយសុំតែងការហាត់ឲ្យសព្វគ្រប់ផង ។

## រង្វាស់រង្វាល់

ក្នុងខែនេះត្រូវបង្វឹកសិស្សឲ្យចេះថ្លឹង

របស់សំរាប់បង្រៀន, - ជញ្ជីងថាសកូនទម្ងន់គីឡូក្រាមរបស់សំរាប់ថ្លឹង ដូចជាដុំថ្មដីខ្សាច់

របៀបបង្រៀន —.

១ - ឲ្យសិស្សលើកដុំថ្មសាកទម្ងន់ ដើម្បីនឹងបញ្ជាក់ឲ្យឃើញខុសត្រូវ ឲ្យសិស្សថ្លឹងនឹងជញ្ជីង ហើយសួរសាកនាំសិស្សនិយាយអំពីរបៀបតើគេធ្វើដូចម្តេច ( ដាក់របស់ត្រូវថ្លឹងទៅលើថាសម្ខាង ដាក់កូនទម្ងន់លើថាសម្ខាងទៀតទាល់តែដងជញ្ជីងត្រង់ស្មើ )

២ - ឲ្យសិស្សថ្លឹងដីខ្សាច់ចំនួន ២ គ.ក្រ. ដាក់កូនទម្ងន់ ២ គ.ក្រ. ថ្លឹងទៅលើថាសម្ខាង ដាក់របស់ត្រូវថ្លឹងទៅលើថាសម្ខាងទៀត ទាល់តែដងជញ្ជីងត្រង់ស្មើ

៣- ការហាត់ - នាំសិស្សរៀនថ្លឹងតាមរបៀបទាំងពីរបែបខាងលើនេះឲ្យចេះស្ទាត់

៤ - ការហាត់សរសេរ - សូមតែងការហាត់នេះឲ្យសមតាមចំណេះផងចុះ ។

ពេលក្រោយៗទៀត ត្រូវបង្ហាត់សិស្សឲ្យរៀនថ្លឹងទៀត តែប្រើជញ្ជីងផ្សេងទៀតដូចជាជញ្ជីងខ្មែរ - ជញ្ជីងប៉ុង

កុមារដ្ឋាន

## វត្ថុស្វាធ្យាយ៍

### អាទិត្យទី ១- អំពីលោហធាតុ

សូមគ្រូយកកំណាត់ដែក, ស្ពាន់, ស្ពាន់ស, សំណ, សំណប៉ាហាំង, ស័ង្កសី, ប្រាក់, មាស, មកបង្រៀន ។

ដូចម្ដេចហៅថាលោហធាតុ គឺស្ពាន់ សំណ សំណប៉ាហាំង ស័ង្កសី ប្រាក់មាសត្រូវយកវត្ថុនេះមកបង្ហាញសិស្សឲ្យពិនិត្យ ។

### លោហធាតុកើតក្នុងដី

ពាក្យចោទ. លោហធាតុនៅទីណា ? នៅជ្រៅក្នុងដី ។ ធ្វើដូចម្ដេច ដើម្បីនឹងយកមកពីក្នុងដីបាន ? គេជីកជាអណ្ដូងជ្រៅ គាស់កកាយយកមក ។ លោហធាតុនៅក្នុងដីសុទ្ធឬទេ ? មានសុទ្ធខ្លះដែរ មាសប្រាក់ ប៉ុន្ដែច្រើនតែលាយនឹងវត្ថុឯទៀត ។

លោហធាតុមានពន្លឺ យកថ្មួយដុំប្រាក់មួយដុំមកឲ្យសិស្សពិនិត្យមើល វត្ថុណាមានពន្លឺ ? លោហធាតុទាំងអស់ សុទ្ធតែមានពន្លឺតិចច្រើនក្ដី ជួនកាលមានពន្លឺនោះក៏រលុបដោយព្រោះចាប់ ស្នឹម ។

លោហធាតុដំបត់បែនឬហូតជាខ្សែបាន តាំងអស់ ៗ ឯងតាំងអស់គ្នា ដែលចូលទៅមើលរោងជាងដែកឬទេ ? ជាងដែកពត់បត់ដែកបាន ដូចម្តេចខ្លះ ? ដំបានជាដុំជាបន្ទះឬជាវត្ថុជាច្រើនផ្សេង ៗ តាមចិត្តបាន ៗ

ដែក មាស ប្រាក់ហូតជាខ្សែបានឬទេ ? ជាងទងហូតមាសបានដូចម្តេច លោហធាតុជាប់ណាស់ ឲ្យសិស្សប្រណ្តាច់ខ្សែលួស ហើយទឹង ខ្សែតំបោះប៉ុនគ្នា ៗ ខ្សែណាជាប់ជាង ? បើគេចង់សង់ស្ពានមួយយ៉ាងមាំ ត្រូវសង់ទឹងដែកឬទឹងឈើ ? លោហធាតុរលាយដោយកំដៅភ្លើងតាំងអស់ ៗ

បើយើងយកសំណប៉ាហាំងមួយដុំទៅដុតក្នុងពែង ដុំនោះក្លាយទៅដូចម្តេច ? ជាងទងរំលាយមាសទឹងកំដៅអ្វី ? លោហធាតុណាឆាប់រលាយជាងគេ ? លោហធាតុនាំកំដៅឆាប់ណាស់ បើអ្នកយកដែកមួយដុំទៅដុតក្នុងភ្លើង ហើយកាន់ចុងម្ខាងនៅដៃ តើអ្នកកាន់បានយូរដែរឬទេ ? តើព្រោះអ្វី ? គឺព្រោះលោហធាតុនាំចំហាយកំដៅបានឆាប់ណាស់ ៗ ហេតុដូចម្តេចបានជាគេចូលចិត្តប្រើឆ្នាំងដែក ឆ្នាំងស្ពាន់ជាងឆ្នាំងដី ៗ

សេចក្តីសង្ខេប.— លោហធាតុគឺ ដែក ស្ពាន់ សំណ ស័ង្កសី ទង់ដែង មាស ប្រាក់ លោហធាតុនៅក្នុងដី លោហធាតុតាំងអស់មានពន្លឺ ដំបត់បែនហូតជាខ្សែបាន លោហធាតុជាប់មាំរលាយបាន ហើយនាំចំហាយពូកែណាស់ ៗ

## អានិត្យទី២ -- អំពីធ្យូងថ្ម

វត្ថុសម្រាប់បង្រៀន - កាំបិតបត់ ញញួរ ធ្យូងថ្ម ធ្យូងឈើ កាកធ្យូងថ្ម ។

នាំសិស្សពិនិត្យមើលធ្យូងថ្ម ពណ៌ដូចម្ដេច ? យកកាំបិតទៅកាត់ធ្យូង ។ សង្កេតឃើញដូចម្ដេច ?

ធ្យូងថ្មមិនស្វិតទេ ។ យកញញួរវាយធ្យូងមួយដុំតូច សង្កេតឃើញដូចម្ដេច ? ឃើញថាធ្យូងថ្មផុយមែន ធ្យូងថ្មនេះ ដុតធ្យូងថ្មមួយដុំនៅលើអំបែងមួយ ធ្យូងនោះឆេះឡើងក្រហមព្រោងឡើងហើយនេះមានចំហាយខ្លាំង ធ្យូងថ្មគឺជាវត្ថុមួយយ៉ាងសំខាន់គេប្រើការដូចម្ដេចខ្លះ ? គេដុតឡកេងម៉ាស៊ីន គេដុតខ្ទះកញ្ចាល ។ កំណើតធ្យូងថ្ម នៅលើធ្យូងថ្មគេច្រើនឃើញស្នាមសន្លឹកឈើ ហេតុដូច្នេះបានជាដឹងថាធ្យូងថ្មកើតមកអំពីដើមឈើ ដែលកប់នៅក្នុងដីជាច្រើនពាន់ឆ្នាំមកហើយ ។

ការជីកយកធ្យូងថ្ម ធ្យូងថ្មមាននៅទីណា ? មាននៅក្នុងដីសណ្ដានជាស្រទាប់ ។ មានចំនួនកប់គីឡូម៉ែត្រទទឹងបណ្ដោយ ។ ដើម្បីនឹងយកធ្យូងពីក្នុងដី គេជីកជារូងជ្រៅទៅក្នុងដី ហើយកាយជីកយកធ្យូងនោះមក ។

ធ្យូងមានច្រើនយ៉ាង គឺធ្យូងថ្មសំរាប់ដុត មានពណ៌សថ្លាកើតឡើងនៅក្នុងដី ។ នៅក្នុងព្រៃឈើយកឧសទៅរៀបដុតក្នុងឡកើតបានជាធ្យូង ហៅថាធ្យូងឈើ ។

## អាទិត្យទី ៣ អំពីអំបិល

វត្ថុសម្រាប់បង្រៀន – អំបិលខ្មៅ អំបិលស កែវ ចាន ត្រីប្រឡាក់

អំបិលខ្មៅជាគ្រាប់ពណ៌ប្រផេះ ។ អំបិលមានជាតិប្រៃអាចនឹងឲ្យរសជាតិដល់អាហារយើង ។

អំបិលនឹងទឹក ត្រូវខ្យល់សើមអំបិលរលាយ ហេតុដូច្នេះ ត្រូវទុកក្នុងប្រអប់បិទជិត ឬក្នុងពាងទើបបានគង់ អំបិលដាក់ទៅក្នុងទឹករលាយបាត់រូប បើយកទឹកប្រៃនេះទៅហាលថ្ងៃ ទឹកហួតអស់ទៅនោះឃើញអំបិលឡើងវិញ កកនៅបាតចាន ។

ស្រែអំបិល ទឹកសមុទ្រប្រៃព្រោះអំបិល ដើម្បីនឹងយកអំបិល គេបញ្ចូលទឹកសមុទ្រទៅក្នុងស្រែ ។ ដល់ត្រូវកំដៅថ្ងៃទឹកហួតទៅនៅសល់គ្រាប់អំបិល គេកើបយកមក ។

អំបិលស នៅក្នុងដីមានគំនរអំបិលស កើតឡើងមកអំពីទឹកសមុទ្រដែលហួតក្នុងដី ដើម្បីនឹងយកអំបិលនេះគេជីករូងគាស់យកអំបិលនេះឡើង ។

ប្រយោជន៍អំបិល ផ្សំជាតិអាហារ ប្រឡាក់ត្រីសាច់ ធ្វើក្បួនស្ងោរខោអាវ ។

អាទិត្យទី ២.– ១ អំពីសិលា

២ អំពីសិប្បយការសិលា

៣ អំពីអណ្តូងយកសិលា

---

## កុមារដ្ឋាន

### វិធីបង្ការរោគ

### អាទិត្យទី១ ការសំអាតបន្ទប់រៀន

សេចក្ដីពន្យល់ – បន្ទប់រៀនគឺជាទីកន្លែងមួយដែលត្រូវឲ្យស្អាតជានិច្ច នាំឲ្យបានសេចក្ដីសុខសប្បាយដល់ខ្លួន បើយើងសំអាតតែរូបកាយយើង ឯកន្លែងយើងអាស្រ័យនៅរាល់ថ្ងៃកខ្វក់នោះ យើងក៏មិនបានសុខសប្បាយចិត្តដែរ ។ ដូច្នេះយើងត្រូវបោសសំអាតបន្ទប់រៀនយើងរាល់ថ្ងៃទើបប្រពៃ ។ បន្ទប់រៀនត្រូវឲ្យស្ងួតឲ្យល្ហើយមានខ្យល់បក់ចេញចូលជានិច្ច ឲ្យមានពន្លឺព្រះអាទិត្យបរិបូណ៌ហើយឲ្យស្អាត ។ បើបន្ទប់រៀននៅផ្ទាល់នឹងដី យើងត្រូវបុកដីឲ្យហាប់កុំឲ្យមានក្រហែងក្រហូងឬដុំដីរដិបរដុបដើម្បីកុំឲ្យដក់ទឹក ។ ដកស្មៅចោលឲ្យអស់កុំឲ្យមានផុះនៅក្បែរជញ្ជាំង បើជាបន្ទប់សង់ខ្ពស់អំពីដីឬក្រាលឥដ្ឋនោះការសំអាតងាយណាស់ ។ សូមគ្រូតែងពាក្យចោទផងចុះ

## អាធិក្យទី ២.– ការបោសប្រាស់

សេចក្ដីពន្យល់ – យើងត្រូវបោសប្រាស់បន្ទប់រៀនរាល់ថ្ងៃ ពេលព្រឹកមុនចូលរៀនឬពេលល្ងាចមុនវេលាទៅផ្ទះ បើបន្ទប់នៅផ្ទាល់នឹងដី យើងប្រើអំបោសរឹង បើបន្ទប់ក្រាលក្ដារឬឥដ្ឋវិញ យើងប្រើអំបោសស្រកីដូង មុននឹងបោសត្រូវប្រស់ទឹកឲ្យសព្វកន្លែង យើងបោសឲ្យល្មមមិនត្រូវវាសអំបោសនោះខ្លាំងពេកទេ ដើម្បីកុំឲ្យធូលីហុយឡើងបាន ៗ យើងត្រូវបោសគ្រប់តំបន់ កនៀតកន្លែងកុំឲ្យសល់ ៗ ប្រមូលសំរាមដាក់មួយដុំ កើបយកទៅចោលនៅកន្លែងចាក់សំរាម លុះបោសស្រេចហើយ បើបន្ទប់ក្រាលក្ដារឬឥដ្ឋ ត្រូវយកបាវជ្រលក់ទឹកឲ្យសើមទៅជូតថែមទៀត ៗ

ចូរកុំភ្លេចបោសសំបុកពីងពាងនៅជញ្ជាំងនឹងពិតាននឹងបោសប្រាស់ក្រោមតុទូផង ៗ

អាធិក្យទី៣.– អំពីបោសធូលីប្រមូលក្រដាស កញ្ច្រែងដាក់ក្រដាសមិនត្រូវដាក់ក្រដាសក្នុងថតតុ ៗ

អាធិក្យទី ៤.– ត្រូវឲ្យមានខ្យល់អាកាស ត្រូវឲ្យមានពន្លឺល្មម ៗ

បង្រៀនសាឡើងវិញ ៗ

បរិច្ឆណាដ្ឋាន

## វត្ថុស្វាធ្យាយន៍

### អាទិត្យទី ១.- ១ អំពីសំពត់

វត្ថុសម្រាប់បង្រៀន.- ផ្លែកប្បាសទុំ អំបោះ ខ្សែអំបោះ សំឡី កំណាត់សំពត់ច្រើនយ៉ាង ៗ

ការវៃអំបោះ គេយកផ្លែកប្បាសទុំទៅធ្វើឲ្យជ្រុះគ្រាប់នៅសល់តែ សំឡី ៗ គ្រូនាំសិស្សពិនិត្យសរសៃសំឡីដែលគ្នារ ទាញយកសរសៃ ពីរឬបីហើយគ្របាញ់ទឹនដៃ បានជាអំបោះនាំសិស្សយកអំបោះមួយសរ- សៃមកលាមើល សរសៃសំឡី ៗ ដើម្បីទឹងវេញជាអំបោះដូច្នេះបាន ស្រួលអ្នកត្បាញមានរហាត់មួយវៃទាញយកសរសៃសំឡីនោះមកវេញ ជាអំបោះ ៗ

ការត្បាញសំពត់ យកសំពត់មកឲ្យសិស្សពិនិត្យមើល សរសៃ អំបោះដែលត្បាញ ហូតអំបោះចាក់មួយម្ដង ៗ បង្ហាញសិស្សមើល ៗ

### ២ អំពីសរសៃឯទៀតដែលត្បាញជាសំពត់

វត្ថុសម្រាប់បង្រៀន.–សំបកធ្នៃ ក្រចៅ ស្នាប់ ធាន់ម្នាស់ ខ្សែធ្នៃ ឬក្រចៅបារ ៗ

ការត្រាំក្រចៅ ដល់ដើមក្រចៅចាស់ គេកាត់ចុងដើមចងជាបាច់ ហើយយកទៅត្រាំទឹកស្ទឹងឬត្រពាំង ដើម្បីជ័រដែលភ្ជាប់សំបកទៅនឹងសាច់ដើមនោះរលាយ ។

ការហូតសរសៃ ដល់ហាលថ្ងៃរួចគេដំឬកិនសរសៃសំបកបែកចេញពីដើម គេបំបែកជាសរសៃឆ្មារ ឯសរសៃនេះគេយកទៅវេញជាអំបោះ ហើយទៅត្បាញជាសំពត់ឬមួយវេញជាខ្សែ ។

សំពត់ក្រចៅក្រាស់ហើយជាប់គេធ្វើជាបាវដាក់ស្រូវពោត ឯផ្ទៃស្អាប់ ក៏ធ្វើរបៀបយ៉ាងនេះដែរ សរសៃម្នាស់ត្បាញបានជាសំពត់យ៉ាងល្អ ។

## អាទិត្យទី ២.- ១... អំពីត្បាញកន្ទេល

វត្ថុសម្រាប់បង្រៀន.– ដើមកក់ស្រស់ កក់ស្ងួត កក់ជ្រលក់ កន្ទេលកក់ពីរបីយ៉ាង កន្ទេលស្លឹកត្នោត កន្ទេលរំបេក កន្ទេលផ្តៅ ។

ដើមកក់មានដុះនៅមាត់បឹងឬមាត់ត្រពាំង គេកាត់ចុងដើម ហូតបន្ទះឆ្មារ រួចយកមកហាលថ្ងៃឲ្យស្ងួត ដល់ស្ងួតហើយទើបយកទៅជ្រលក់ពណ៌រួចយកមកត្បាញ ។

ឯខ្សែអន្ទង់គឺខ្សែធ្មៃ បើចង់ធ្វើគោមឬផ្កា គេគោងបាក់កក់ផ្លាស់ពណ៌គ្នា ៗ គេយកកក់មកត្បាញ កើតជាកន្ទេលចចូតឬកន្ទេលកន្ទៀង

កន្ទេលរំពេកធ្វើអំពីធាងរំពេក កន្ទេលស្លឹកត្នោតធ្វើអំពីស្លឹកត្នោត ៗ បើចង់បានកន្ទេលជាប់យូរឆ្នាំ គេយកចំរៀកផ្ដៅ ច្រើនមានធ្វើនៅស្រុកបាត់ដំបង ៗ

## អាទិត្យទី ៣.- ការស្រាវសូត្រ

### អំពីត្បាញសំពត់សូត្រ

វត្ថុសម្រាប់បង្រៀន.– សំបុកដង្កូវនាង សូត្រដុំ សរសៃសូត្រ សំពត់សូត្រសំពត់ព្រែងទៀត. ៗ

សូត្រដែលស្រាវយកមកពីសំបុកនាង គេយកមករវៃនាំសិស្សពិនិត្យមើលសរសៃសូត្រឆ្មារ ៗ. ហើយសរសៃនោះមកវេញនឹងដៃសរសៃនេះវេញគួបគ្នាទៅបានជាសរសៃសូត្រយកមកត្បាញបាន. ៗ

បើចង់បានពណ៌គេយកសូត្រទៅជ្រលក់ ឯរបៀបត្បាញនោះក៏ដូចជាត្បាញសំពត់អម្បោះដែរ សូមគ្រូពន្យល់សិស្សរបៀបត្បាញម្ដងទៀតឲ្យជាក់ច្បាស់ ឯសូត្រគេត្បាញបានជាសារុង សំពត់ហូល ល្បើក ៗល។ ដើម្បីឲ្យសិស្សបានយល់សំពត់សូត្រនេះហៅថាសំពត់សូត្រសុទ្ធ ៗ

នៅផ្សារមានលក់សំពត់ព្រែច្រើនថែប ដែលមិនមែនជាសូត្រ ៗ

# អំពីសំពត់ធ្វើអំពីរោមចៀម

វត្ថុសម្រាប់បង្រៀន.- រោមចៀម អំបោះចាក់ហើយនឹងអាវធ្វើអំពីរោមចៀម (សាក្លាត)

នាំសិស្សពិនិត្យមើលសរសៃរោម សរសៃនេះធ្មារដូចជាសរសៃសំឡីកប្បាសឬសរសៃសូត្រ

ហេតុនេះបានជាគេយកធ្វើសំពត់បាន ដូចជាសំពត់កប្បាសឬសំពត់សូត្រ ។

មុនដំបូងគេកាត់រោមនោះយកមកលាង លាបប្រេងសិតធ្វើជាបន្ទះមួយវែង រួចគេយកទៅដុសសាប៊ូហើយទាញជាអំបោះរួចសិតទៀត ដល់បានជាអំបោះគេយកមកត្បាញ ។

ឯរបៀបនោះក៏ដូចជាត្បាញសំពត់ធម្មតា នាំសិស្សពិនិត្យមើលអំបោះធ្វើអំពីរោមចៀម ហើយនឹងសំពត់សាក្លាត ។ អំបោះនេះគេយកចាក់ជាអាវយឺតក៏បាន ធ្វើជាភួយឬព្រំក៏បាន រោមពពែម្យ៉ាងហៅថារោមពពែ "អង្គរ៉ា" ល្អជាងរោមចៀមទៅទៀត, សំពត់រោមចៀមឬរោមពពែ ក្រាស់ហើយកក់ក្ដៅ, គេយកកាត់ខោអាវរងារ ។

## អាទិត្យទី ៤ អំពីជ្រលក់សំពត់

វត្ថុសម្រាប់បង្រៀន- មកឿ មរ រមៀត សំបកព្រហូត ខ្ទឹមខ្មុរ ល័ក្ខគ្រប់មុខ។ល។

សាបង្រៀនពីដើមឡើងវិញ

---

បរិច្ឆណដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យទី ១.- និងទី ២.- អំពីការសំអាតសំលៀកបំពាក់

សុំមើលសៀវភៅវិធីបង្ការរោគទំព័រទី ១៤ មើលឲ្យសិស្សស្តាប់ ហើយ និយាយពន្យល់សួរតាមពាក្យខាងក្រោមនេះ ៗ

ពាក្យចោទ.- បើឯងប្រើខោអាវតែមួយបន្តុះយូរថ្ងៃទៅឯងមានធុំក្លិនអ្វី ? ក្លិនអាក្រក់ទាំងនេះកើតមកអំពីអ្វី ? ខោអាវដែលមានញើសឬក្អែលកាន់ជាទិច្ចនោះជាប់បានយូរឬទេ ? បើចង់ឲ្យខោអាវស្អាតជានិច្ចត្រូវលាងបែបណា ? គេស្ងោរលាងសំអាតអាវដូចម្តេច ? បើគ្មានសាប៊ូប្រើអ្វីជំនួសបាន គេលាយទឹកក្បុងកាតយ៉ាងណា ?

### អាទិត្យទី ៣.- ត្រូវស្លៀកពាក់ដូចម្តេច

ពាក្យចោទ.- ដូចម្តេចបានជាត្រូវស្លៀកពាក់ខោអាវទូលាយ ?

សំលៀកបំពាក់ ដែលធ្វើតាមវិធីបង្ការរោគមានសណ្ឋានយ៉ាងណា ? សំពត់ត្បាញរបៀបយ៉ាងណាដើម្បីឲ្យមានខ្យល់ចេញចូលស្រួល ស្បែកជើងអ្នកត្រូវរើសរកយ៉ាងដូចម្ដេច ? វេលាក្ដៅ វេលាល្ងាចត្រូវស្លៀកពាក់ដូចម្ដេច ។

អាធិត្យទី៤.— សាបស្រៀនជាថ្មីឡើងវិញ

---

## អាធិគដ្ឋាន

## វិត្តស្វាធ្យាយន៍

### អាធិត្យទី ១.- ដីសនិងថ្មកំបោរ

ចូរអ្នកយកដីសមួយដុំ ហើយអ្នកបោះវាទៅក្នុងពែងទឹកខ្មេះខ្លាំងនេះ អ្នកក៏ឃើញមានពពុះចេញពីដីសនោះ ឡើងមកមួយរំពេចបែកខាងលើ ហើយបណ្ដាលឲ្យទឹកខ្មេះនោះពុះឡើង ។

ចូរអ្នកដាក់ដុំថ្មកែវមួយដុំតូចក្នុងទឹកខ្មេះទៀត ថ្មនេះរឹងណាស់ប៉ុន្តែគង់តែទឹកខ្មេះរំលាយវាបានឲ្យចេញពពុះដែរ ។

មួយយ៉ាងទៀតក្នុងពែងទឹកខ្មេះនេះ បើអ្នកដាក់ដុំឥដ្ឋវិញឬគ្រួសក្ដី ហើយរឺមួយដុំ ដែលឃើញនៅក្នុងដីខ្សាច់ទឹកព្រែកហូរនាំយកពីភ្នំមក នោះ គ្មាន.ឃើញបែកពពុះទេ ដូចជាដាក់ក្នុងទឹកសុទ្ធដែរ ។

ធ្វើដូច្នេះនឹងទឹកម្ជូរណាដែលខ្លាំងជាងទឹកខ្មេះទៅទៀត នោះយើងក៏នៅតែឃើញដូចជាធ្វើល្បងនឹងទឹកខ្មេះដែរ ។

ថ្មមានពីរយ៉ាង៖ ១.– គឺថ្មបែកពពុះរលាយក្នុងទឹកម្ជូរ ។

២.– គឺថ្មមិនបែកពពុះរលាយក្នុងទឹកម្ជូរ ។

ថ្មបែបមុននោះហៅថាថ្មកំបោរ ឯថ្មបែបក្រោយហៅថាថ្មដែកកើង ថ្មឥដ្ឋក៏មិនបែកពពុះរលាយក្នុងទឹកម្ជូរដែរ ។

ថ្មកំបោរជាតិវាជាអំបិល កំបោររលាយនឹងធាតុខ្យល់មួយយ៉ាង បាក់ង ហៅថា "ឧស្ម័នការបូនិក" (gaz carbonique) ហើយនឹងកំបោរឯង ដូច្នេះបានជា កាលណាគេដាក់ទៅក្នុងទឹកម្ជូរ ឃើញមានបែកពពុះឡើង ឯពពុះនេះគឺពពុះធាតុខ្យល់ "ឧស្ម័នការបូនិក" (gaz carbonique) ហុយចេញមកថ្មកំបោរផុយណាស់ គេឆូតនឹងដែកថែប ឬនឹងដែកអ្វីបាន លុះគេដុតទៅថ្មនោះរំលែកទៅ ជាធាតុខ្យល់ (ឧស្ម័នការបូនិក) ហុយចេញទៅ ហើយនៅតែកំបោរហៅថាកំបោររស់ កំបោរនេះកាលណាត្រូវទឹកទៅជាកំបោរផុសឬកំបោរឆាប់ ។ គេយកកំបោរផុសនេះមកលាយនឹងទឹកហើយនឹងដីខ្សាច់ បានជាបាយអថ្មកំបោរដែលគេស្គាល់ច្រើននោះ គឺថ្មសំរាប់ធ្វើកំបោរ ថ្មសំរាប់សង់គ្រឹះស្ពានដីស ថ្មផ្ដិតពុម្ពហើយនឹងថ្មកែវ ។

## អាទិត្យទី ២.– ដីឥដ្ឋនិងការធ្វើឥដ្ឋធ្វើក្បឿង ។

គេយកដីឥដ្ឋមកលាយនឹងទឹក ហើយច្របាច់ឲ្យទន់ទើបចាក់ពុម្ពរួចយកទៅដុតឲ្យរឹង គេធ្វើបាននឹងដីឥដ្ឋសសុទ្ធ ដីឥដ្ឋឯទៀតមិនសូវល្អ គេយកមកធ្វើជាចាន ឆ្នាំងក្អម ក្បឿង ឥដ្ឋ ឥដ្ឋពណ៌ ។ល។ នៅក្នុងរោងធ្វើការបាក់ងវិសេស ការនេះគេធ្វើនឹងម៉ាស៊ីន ។

## អាទិត្យទី ៣.– អំបិលនិងកែវ

### មេរៀនទី ១.– អំបិល

អំបិលជាវត្ថុ ១ ហើយរឹងសម្បុរស ឬប្រផេះហើយរលាយក្នុងទឹក គេធ្វើអំបិលនឹងទឹកសមុទ្របញ្ចូលក្នុងស្រែទុកឲ្យហួតរឹង ឬគេយកទឹកនោះទៅរំងាស់ គេហៅថា (sel marin) ស្រុកខ្លះដូចជាស្រុកលាវ គេយកអំបិលពីក្នុងដីកន្លែងណាដែលគេជីករួចជាអណ្តូង គេហៅថា (sel gemme) ។

ក្នុងប្រទេសឥណ្ឌូចិនមានស្រែអំបិលទៅតាមឆ្នេរសមុទ្រស្រុកតុងកឹង ខាងជើងនឹងខាងត្បូងស្រុកអាណាម ហើយនឹងស្រុកកូសាំងស៊ីន ។

### មេរៀនទី ២.– កែវ

ក) ការធ្វើកែវ– គេលាយដីខ្សាច់ជាមួយនឹងអំបិលមួយយ៉ាង ហៅថា (សូត) ហើយនឹងផង់ដីសយ៉ាងម៉ដ្ឋ ហើយដុតវត្ថុទាំងអស់នេះ ក្នុងឡយ៉ាងក្តៅ ។ វត្ថុនេះរលាយទៅជាវត្ថុរាវ ដែលគេអាចយកទៅចាក់ពុម្ពធ្វើ ១ បានតាមចិត្ត ។

១) លក្ខណរបស់ដែក-ការប្រើប្រាស់ដែក

១) ដែកមានសាច់ធ្ងន់ (អាចធ្វើជាកញ្ចក់) ដែកវែនតា....តែ គេអាចធ្វើឲ្យមានជាពណ៌ផ្សេងៗ បាន ។

២) ដែកមានសាច់រឹងណាស់ យើងពុំអាចឆូតនឹងក្រចកឬនឹងកាំបិតដាច់ឡើយ ។

គេកាត់កញ្ចក់បានដោយថ្មពេជ្រ ឬនឹងដែកថែបយ៉ាងរឹង ។

៣– ដែកមានសាច់ស្រួយ, ធ្លាក់ឬត្រូវភ្លើងក្តៅបែក ។

៤– ដែកបញ្ចេញសូរខ្ទរកាលណាគេគោះ

## អាទិត្យទី៤.- អណ្តូងយកថ្ម ថ្មសំរាប់ដុត ការជីកយកធ្យូងថ្ម

ធ្យូងថ្មគេដុតបាន គេយកធ្យូងនេះនៅលើដី ឬ នៅក្នុងដី ។ ធាតុដែកនៅក្នុងដីលាយនឹងវត្ថុទៀតជាច្រើន នៅស្រុកតុងកឹងមានដែកស័ង្កសី សំណប៉ាហាំង ស្ពាន់ ច្រើនណាស់ ។

នៅស្រុកអាណាមមានដែកក្នុងខេត្តវិញ (Vinh) ហើយនឹងស័ង្កសីក្នុងខេត្តខ្វាងណាម ។ នៅស្រុកខ្មែរមានដែកនៅភ្នំដែក (ខេត្តកំពង់ធំ) នៅស្រុកលាវមានដែកច្រើនក្រៃ មាសនៅលាយនឹងដីខ្សាច់ មានមាសនៅក្នុងខេត្ត "បុងមៀវ" ស្រុកយួន (អាណាម)

# វិធីបង្ការរោគ

## អាទិត្យទី ១.— ជំងឺគ្រុនចាញ់

ចូរអ្នកដាក់មុងដេកប្រយោជន៍ការពារខ្លួនអ្នក កុំឲ្យមូសខាំបាន មូសមិនសូវស្មោកគ្រោកដូចរុយទេ ប៉ុន្តែជាសត្វបណ្ដាលឲ្យអន្តរាយសេចក្ដីសុខសប្បាយយើងដែរ មានមូសខ្លះបណ្ដាលឲ្យមនុស្សឈឺគ្រុនចាញ់ស្លាប់ជាច្រើនរាល់ឆ្នាំ គឺមូសនេះហើយជាមេបំផ្លាញធំនៅក្នុងស្រុកយើង មូសបណ្ដាលឲ្យគ្រុនចាញ់នោះ ងាយនឹងសំគាល់ទេ វាទំនៅកន្លែងណា នោះបំបះគូថឡើងលើស្ទើរតែនឹងត្រង់ស្មោះ ៗ មូសណាខាំមនុស្សគ្រុនហើយមកខាំអ្នកទៀត មូសនោះអាចនឹងចម្លងជំងឺគ្រុនអ្នកនោះមកអ្នក ពីព្រោះវាផ្ទុកយកឈាមមនុស្សគ្រុននោះដោយទាំងមេរោគមកបញ្ចូលក្នុងសាច់អ្នកផង បើមនុស្សគ្រុនដាក់មុងបិទបាំងការពារខ្លួនឲ្យជិត មូសខាំមិនបានទេ ដូច្នេះវាមិនបាននាំមេរោគគ្រុនមកឲ្យអ្នកឡើយ កុំដេកក្នុងព្រៃឥតមុងឬគ្មានដុតភ្លើងឲ្យហុយផ្សែងដេញមូសចេញផង ៗ

## អាទិត្យទី២.— ជំងឺពិសបារាំងហៅថាប៉េស្ត

គោលសេចក្ដី— ជាជំងឺកាចក្លាត ដែលធ្លងមកពីប្រទេសចិន តាមទូកដោយសារកណ្ដុរ ៗ កើតមានជានិច្ចនៅយូនណាន់នឹងប្រទេសក្នុង

១)– លក្ខណៈ :- ឡើងកូនកណ្ដុរប៉ុនពងមាន់នៅត្រង់ក្លៀកនិង ត្រង់ក្រលៀនអ្នកជម្ងឺគ្រុនសន្ទប់សន្ទិន ។

២)–ហេតុ– បណ្ដាលពី "អតិសុខុមប្រាណយែរសាំង" តែងកើត លើរូបកណ្ដុរនៅក្នុងដី ហើយឆ្លងមកមនុស្សដោយចៃវាខាំ ។ ខ្ទុះកូន កណ្ដុរដែលហើមនៅក្លៀកនិងក្រលៀនមានមេរោគច្រើនក្រៃលែង ខ្ទុះនេះ នាំឲ្យឆ្លងផុតឆាប់ណាស់ ។

### ៣) កិច្ចការពារ

ក )- ឲ្យមនុស្សជម្ងឺនៅដោយឡែក ។

ខ )- ដាក់លាមកនិងទឹកមូត្រក្នុងកន្ធោរមានទឹក " ក្រេស៊ីល " ហើយចាក់កប់ក្នុងរណ្ដៅជំរៅ ១ម មានលាយកំបោរផង ។

គ )- កប់ខ្មោចស្លាប់និងជម្ងឺនេះក្នុងរណ្ដៅជំរៅ ២ ម ចាក់កំបោរពី លើផង

ឃ )- បាចផ្ទះនិងទឹកកំបោរ ស្ងោរប្រដាប់ដែលអ្នកជម្ងឺប្រើ ។

ង.)- ត្រូវចាក់ថ្នាំ ។

ច )- សំឡាប់កណ្ដុរហើយដុតចោល ។

## អាទិត្យទី ៣.– ត្រូវធ្វើកុំឲ្យមានចៃ

មានចៃពីរយ៉ាង ចៃក្បាល ១ យ៉ាង ចៃខ្លួនឬចៃសំពត់អាវ ១ យ៉ាង ចៃទាំងអស់សុទ្ធតែស្មោកគ្រោកដូចគ្នា គួរឲ្យខ្ពើមណាស់ ចៃក្បាល

ច្រើននៅក្នុងផ្ទៃសក់ ច្រើននៅក្នុងក្បាលមនុស្សណាដែលមានសក់វែង ចៃខ្លួនឬចៃសំពត់អាវច្រើនមាននៅដោយសំលៀកបំពាក់ ហើយចូលចិត្តនៅតែនឹងសំលៀកបំពាក់ណាដែលប៉ះពាល់ផ្ទាល់នឹងស្បែក លុះវាទៅមកជញ្ជក់យកឈាមជាអាហារបាន ចៃនេះច្រើននៅត្រង់ផ្នត់ឬត្រង់ថ្នេរសំពត់អាវ ហើយវាពងនៅទីនោះជាច្រើនផង លុះញាស់ទៀតមានចៃផ្តុំគ្នាជាសំបុកធំ ៗ ចៃខាំហើយបង្កើតឲ្យរមាស់អេះទាល់តែរបកស្បែកឬចេញឈាម ចៃមាននៅនឹងអ្នកណាមិនគ្រាន់តែបណ្ដាលអ្នកនោះឲ្យស្មោកគ្រោកប៉ុណ្ណោះទេ ថែមទាំងមានអន្តរាយដល់ខ្លួនអ្នកនោះនឹងអ្នកនៅជាមួយផង ៗ កាលណាចៃខាំមនុស្សមានជម្ងឺតាំងពីដំបូងដូចមានខាងលើនេះហើយ ចៃនោះទៅខាំមនុស្សណាទៀត វាចម្លងជម្ងឺនោះទៅមនុស្សនោះផង ម្យ៉ាងទៀតការឆ្លងជម្ងឺនេះផ្លូវណាកើតអំពីមនុស្សមានចៃអេះកន្ទួលដែលចៃខាំជាប់ពិសនឹងក្រចកដៃ ហើយទៅអេះឲ្យអ្នកដទៃទៀត ពិសនោះជាប់នឹងក្រចកដៃទៅចូលក្នុងសាច់គេក៏ឆ្លងតជម្ងឺទៅ ៗ

## អាទិត្យទី ៤០.- ជម្ងឺកមរមាស់

គោលសេចក្ដី.- ជាជម្ងឺស្បែកឆ្លងបានដោយងាយ ៗ

១- លក្ខណៈ ដំបូងរមាស់ មានកន្ទួលត្រង់ចង្កេះក្រោមដៃ, កដៃ កែងដៃ រួចពេញខ្លួន ៗ

២- ហេតុ - បណ្ដាលពីសុខុមសត្វពួកដូចសត្វពីងពាង ។ ញីវាពងក្នុងសាច់បង្កើតជាកូនបានឆាប់ណាស់ ។

៣) កិច្ចការពារ

ក ) កុំឲ្យអេះ ។

ខ ) ដុសខ្លួននឹងសាប៊ូខ្មៅ ដោយគួតយ៉ាងខ្លាំង ដើម្បីកំចាត់ពងមេរោគចេញ រួចលាបថ្នាំដែលមានលាយស្ពាន់ធ័រ ផ្អាប់ហោលស្អក ឡើងសឹមលាងទឹកក្ដៅចេញ ។

គ ) ស្លៀកពាក់តែខោអាវដែលស្ងោរស្អាត ។

---

លោកនីតិ

សម្រាប់គ្រប់ថ្នា

---

១) អំពីរបៀបតុលាការ -

គ្រប់ប្រទេសទាំងអស់ មានក្រុមតុលាការសំរាប់ជំនុំជំរះកាត់សេចក្ដីពិន័យឬធ្វើទោសជនណាដែលប្រព្រឹត្តបទល្មើសនឹងច្បាប់ ឬកើតហេតុទាស់ទែងនឹងគ្នា ។

ប្រទេសកម្ពុជាយើង របៀបតុលាការមានពីរបែបគឺក្រុមតុលាការខ្មែរនឹងក្រុមតុលាការបារាំង ។ ក្រុមតុលាការខ្មែរជំនុំជំរះតែជាតិខ្មែរនឹងខ្មែរកើត

វិវាទនឹងគ្នា បើជាតិខ្មែរនឹងជាតិដទៃកើតហេតុនឹងគ្នា នោះត្រូវប៉ែកខាងតុលាការបារាំងជំនុំជំរះវិញ ។

ក្រុមតុលាការខ្មែរមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ( លោកឃោមពង ) នាយកត្រួតត្រា ហើយក្រុមទាំងនោះមានច្រើនថ្នាក់ឬប៉ែកឯទៀតផង ដូច សាលាលហុ សាលាដំបូង សាលាក្រុមទោស សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ និងសាលាវិនិច្ឆ័យ ។

សួរចោទ ៖ - នៅប្រទេសយើងមានក្រុមតុលាការឬទេ ? ពីព្រោះអ្វីបានជាមានរបៀបតុលាការ ? បើខ្មែរនឹងខ្មែរទាស់ទែងគ្នា ត្រូវទៅប្ដឹងក្រសួងណាមុនដំបូង ? បើមេឃុំផ្សះផ្សាមិនព្រមជានឹងគ្នា ត្រូវទៅប្ដឹងឯណាទៀត ? បើខ្មែរនឹងចិនឬនឹងយួនកើតវិវាទនឹងគ្នា ត្រូវទៅប្ដឹងឯណា ? រដ្ឋមន្ត្រីណាដែលជានាយកលើក្រុមតុលាការទាំងអស់ ? មានមន្ទីរនៅត្រង់ណា ? ចូររៀបរាប់សាលាជំនុំជំរះនៅប្រទេសកម្ពុជា ។ល។

## សាលាលហុ

សាលាលហុ មិនមែនគេតាំងនៅគ្រប់ខេត្តទេ ខេត្តខ្លះមាន ខ្លះគ្មាន ហើយច្រើនតាំងនៅកន្លែងណាដែលឆ្ងាយពីសាលាដំបូងផង មានចៅក្រមក្រសួងតុលាការម្នាក់ជាចាងហ្វាង ។ សាលាលហុមានអំណាចកាត់សេចក្ដីក្ដីទោសដាក់គុកកំណត់ពី ១ ថ្ងៃទៅដល់ ៥ ថ្ងៃយ៉ាងច្រើន បើគូក្ដីមិនសុខ

ចិត្តនឹងប្ដឹងសុំទៅឧទ្ធរណ៍បាន ប៉ុន្តែបើទោសល្មើសនោះត្រូវពិន័យជាប្រាក់វិញយ៉ាងតិច ៤០ សេន យ៉ាងច្រើន ៥ រៀលនោះ ឥតមានបើកផ្លូវឲ្យឧទ្ធរណ៍ទេ បើគូវិវាទមិនសុខចិត្តនឹងទោសលក់ពិន័យនេះ នឹងមានអំណាចប្ដឹងទៅសាលាវិនិច្ឆ័យបាន ។

បើរឿងណាជាបទវដ្ដប្បវេណី គឺទាស់ទែងកេរ្តិមតិកជាដើមហើយដម្លៃវត្ថុនោះតិចពី ១០០ រៀលចុះមក នោះសាលាលហុនឹងកាត់សេចក្ដីសម្រេចបានឥតទុកផ្លូវឧទ្ធរណ៍ បើគូក្ដីមិនសុខចិត្តនឹងសុំទៅសាលាវិនិច្ឆ័យបាន ។ បើដម្លៃនោះលើសពី ១០០ រៀលឡើងទៅឬដម្លៃមិនបានច្បាស់ប្រាកដទេ ត្រូវកាត់សេចក្ដីទុកផ្លូវឧទ្ធរណ៍ ។ ឯរឿងឧទ្ធរណ៍ដែលគូក្ដីមិនសុខចិត្តនឹងសាលាលហុត្រូវធ្វើពាក្យឧទ្ធរណ៍ យកទៅប្ដឹងសាលាដំបូងដែលសាលាលហុនោះត្រូវឡើង ។

## មេរៀនសង្ខេប.— សាលាលហុ.

សាលាលហុសំរាប់ជំនុំជំរះបទលហុ គឺទោសល្មើសធ្វេសប្រហែសនឹងច្បាប់បញ្ញត្តិ មានអំណាចកាត់សេចក្ដីធ្វើទោសពី ១ ថ្ងៃទៅដល់ ៥ ថ្ងៃយ៉ាងច្រើនទុកផ្លូវឧទ្ធរណ៍ បើពិន័យជាប្រាក់វិញយ៉ាងតិចត្រឹម ៤០ សេន យ៉ាងច្រើនត្រឹម ៥ រៀលឥតទុកផ្លូវឧទ្ធរណ៍ទេ ប៉ុន្តែបើនឹងប្ដឹងទៅសាលាវិនិច្ឆ័យបាន ។

បើជើងក្តីនោះចូលជាបទរដ្ឋប្បវេណីវិញ មានថ្លៃមិនលើសពី ១០០ រៀលទេ សាលាលហុកាត់សេចក្តីសម្រេចបានឥតមានទុកផ្លូវឧទ្ធរណ៍ តែបើថ្លៃក្តីនោះពុំបានច្បាស់ប្រាកដទេឬលើសពី ១០០ រៀលឡើងទៅត្រូវកាត់សេចក្តីទុកផ្លូវឧទ្ធរណ៍ ។

សួរហាត់ ៖.- សាលាលហុច្រើនមានតាំងនៅកន្លែងណា ? សាលាលហុសំរាប់កាត់សេចក្តីដាក់គុកបានប៉ុន្មានថ្ងៃ ? ពិន័យប៉ុន្មានរៀល ? បើកាត់សេចក្តីដាក់គុក ហើយអ្នកជាប់ទោសមិនសុខចិត្ត ត្រូវប្តឹងទៅឯណាទៀត? ចុះបើមិនសុខចិត្តនឹងសាលានេះពិន័យលក់វិញ ត្រូវប្តឹងទៅឯណាទៀត ។ ល ។

---

មេសូត្រត់មាត់

(សម្រាប់គ្រប់ថ្នាក់)

## ១ សិស្សត្រូវដឹងគុណគ្រូ

នែសិស្សទាំងឡាយ គុណគ្រូបាធ្យាយ មានទម្ងន់ណាស់
បង្ហាត់បង្រៀន សព្វអក្សរសាស្ត្រ ចូរចាំឲ្យច្បាស់
គុណលោក ៥ នេះ ។ មួយខំបង្រៀន ពីរខំទូន្មាន
កុំឲ្យប្រហែស បីមានមេត្តា អាណិតអ្នកនេះ
បួនអរអ្នកចេះ ប្រាំមិនខ្លាចនឿយ ។

## ២– ចូរអ្នកធ្វើកិច្ចធុរៈអ្នក

សិស្សអើយយើងប្រាប់ ចូរអ្នកប្រុងស្តាប់ យកទៅពិចារណ៍
ឪពុកម្តាយអ្នក ប្រឹងខំធ្វើការ ចិញ្ចឹមអាត្មា
នឹងចិញ្ចឹមអ្នក ។ ចំណែកអ្នកវិញ ត្រូវខំបំពេញ
កិច្ចការធុរៈ ពុំទាន់សំរេច ចូរកុំទម្លាក់
ចាកកិច្ចធុរៈ ខំប្រឹងរៀនទៅ ។

ពាក្យពន្យល់.– ពិចារណ៍: ម.ថ.ពិចា ។ អាត្មា: ខ្លួន... ខ្លួនឯង ។

## ៣– សេចក្តីទៀងត្រង់

ចូរអ្នកប្រព្រឹត្ត អំពើសុចរិត ទៀងត្រង់ប្រពៃ
សេចក្តីប្រសើរ នេះមិនឲ្យភ័យ សុខសប្បាយក្រៃ
សុខឥតទុក្ខ ។ កុំលាក់កុំលួច ទ្រព្យគេមិនរួច
នឹងទុកឡើយណា បើរើសឲ្យយក ដាក់ផ្ទះរាជការ
ទើបបានសុខសារ ឥតមានទោសពៃរ៍ ។

ពាក្យពន្យល់.– ប្រសើរ= ប្រពៃ ។ សារ= (ន) បុណ្យ ។

## ៤– ត្រូវគោរពពាក្យសច្ចៈជានិច្ច

ពាក្យសត្យពាក្យសន្យា ជាពាក្យទៀងត្រង់ ឥតប្រែត្រឡះ
ពេលហើយយ៉ាងណា ត្រូវចាំឲ្យច្បាស់ ពេលក្រោយកុំប្រាស

ពាក្យចាស់ពោលមុនៗ  បើសិនសរសេរ  ចូរអ្នករិះរេ
គ្នាន់គ្នេរគិតគន់  លុះយល់ថាត្រូវ  ឥតស្កកខកស្កុន
ថ្ងៃក្រោយថ្ងៃមុន  ពោលពិតប្រាប់គេៗ

ពាក្យពន្យល់. សត្យ= (ម.ថ ស័ត) ពាក្យសច្ចៈ, ពាក្យពិតៗ
ពោល= និយាយ, ស្ដី, ថាៗ គ្នាន់គ្នេរ= គឺគ្នេរ
គិតលៃលកមើលៗ

## ៥- ចូរសិស្សជៀសវាងកិរិយាអាក្រក់

សិស្សអើយលោកពោលថា  កិរិយាខាងក្រោមនេះ
ចិត្តធំ,ធ្វេសប្រហែស,  ឆ្មើងកន្ទ្រើង,ឥតសណ្ដាប់ៗ
កំណាច,ចចេសរឹង,  ច្រើនតែខឹងធុរឆេវឆាប់,
បង្អាប់គេខុសច្បាប់,  ខ្ជិលច្រអូស,ឥតគំនិតៗ
ចំអក,ពោលកុហក  ពាក្យលាមកថាជាពិត
ចូរវៀរកុំប្រព្រឹត្ត  ទើបបណ្ឌិតថាសិស្សល្អៗ

ពាក្យពន្យល់.- ធុរឆេវ= គឺខឹងខ្លាំងដូចជាចាប់តែឆេវៗ ៗ
លាមក= អាក្រក់, ពុំប្រសើរ ៗ
បណ្ឌិត= អ្នកប្រាជ្ញ ៗ

## ៦– សេចក្តីចំរើនរបស់ក្រុមបណ្តាជន

ការនៅជួបជុំគ្នា ជាចរិយា នាំក្សេមក្សាន្ត
ចិញ្ចឹមជីវិតបាន វង្សថ្កើងថ្កានប្រសើរក្រៃ ។
វិជ្ជាក៏បានចេះ មានចំណេះពេញហឫទ័យ
ចេះច្បាប់សណ្តាប់ថ្ងៃ អាចវិនិច្ឆ័យរកខុសត្រូវ ។
បើជួបជុំគ្នាហើយ ពុំមានឡើយការណ៍អាស្រូវ
ចូរសិស្សចាំទុកទៅ កុំបីនៅតែម្នាក់ឯង

ពាក្យពន្យល់.– ចរិយា= (ម.ថ ចះ–រិ–យា) ការប្រព្រឹត្ត ។ វង្ស= ពូជ, ត្រកូល, ក្រសែ ។ ហឫទ័យ=(ម.ថ ហះ-ឫ-ទៃ) ចិត្ត,ដួងចិត្ត ។ វិនិច្ឆ័យ= (ម.ថ វិះ-និច-ឆ័យ)ការពិចារណាដោយល្អិត,ការពិនិត្យមើលឲ្យឃើញពិត ។ ការណ៍= (ម.ថ.ការ) ហេតុ, ដំណើរ ។

រោងពុម្ពខ្មែរ